# កិច្ចសម្ភាសរបស់លោកតាជា អឿ
កៈ អ្នកសម្ភាសឈ្មោះ ហេង សុជីវី ខៈ
អ្នកដែលត្រូវគេសម្ភាសជា អឿ

កៈ ចាស!មុនដំបូងសូមជំរាបសួរកុង!
ខៈ បាទ!សុខសប្បាយ!
កៈ
ចាសកុង!នៅក្នុងថ្ងៃនេះខ្ញុំបានមានឳកាសដើម្បីនឹងធ្វើការសម្ភាសដល់កុង!ហើយខ្ញុំបានធ្វើការងារស្មគ្រ័ចិត្តរបស់ខាងសាលាBYUនៅខាងសហរដ្ឋអាមេរិកគំរោងរបស់ខាងសាលាមួយនឹងគឺចង់ជួយចង់ក្រងពង្សប្រវិត្តរបស់កុងហើយនឹងអឺ!...ដូចជាខ្សែជីវិតរបស់កុងតាំងពីមុននឹងមកដល់ឥឡូវតើកុងមានបទពិសោធន៍នឹងមានខ្សែជីវិតដើម្បីនឹងទុកអោយកូនចៅជំនាន់ក្រោយគេបានស្តាប់។
កៈ បាទ!
ខៈ
ចាស!ចឹងតើកុងអនុញ្ញាតអោយចៅធ្វើការសម្ភាសកុងអឺ!...ដោយការថតជាសំលេងរបស់កុននឹងមានជារូបថតរបស់កុងយកទៅដាក់នៅក្នុងខាងវេបសាយរបស់ខាងសាលាដើម្បីនឹងទុកអោយកូនចៅជំនាន់ក្រោយនឹងគេបានស្តាប់ដែរឬទេកុង?
ខៈ បាទយល់ព្រមអរគុណ!
កៈ
ចាស!ចឹងជាដំបូងនៃការសម្ភាសគឺការសម្ភាសនៅក្នុងថ្ងៃនេះនឹងគឺជាថ្ងៃទី៣១ខែ៧ឆ្នាំ២០១៨ហើយនឹងចឹងការសម្ភាសជាមុនដំបូងនឹងចៅសូមឈ្មោះកុងតើកុងមានឈ្មោះអ្វីដែរកុង?
ខៈ បាទចៅ!ជំរាបចៅអោយបានច្បាស់ខ្ញុំបានមានឈ្មោះថាអឺ! ជា
អឿននឹងជាឈ្មោះកាលពីដើម!។
កៈចាស!
ខៈ ហើយបានមកដល់ពេលបច្ចុប្បន្ននឹងគេបានហៅថាជា អឿ!។
កៈ ចាស!
ខៈ នឹងហើយចំណែកឯឪពុកវិញនឹងមានឈ្មោះថា រស់ជា
ហើយនឹងម្តាយមានឈ្មោះថា ឡុង លុន។
កៈ ចាស!
ខៈ ហើយបានរស់នៅឯក្នុងភូមិក្រាំង ឃុំព្រៃសន្លឹក នៅក្នុងស្រុកពារាំង
នៅក្នុងខេត្តព្រៃវែង។
កៈ ចាស!
ខៈ
ហើយកាលពីនៅតូចនឹងកាលដែលខ្ញុំនឹងនៅពីកុមារភាពនឹងកាលនឹងខ្ញុំនឹងបានសិក្សានៅក្នុងថ្នាក់ឧត្តមហាននឹងណា!កាលនឹងបានរៀនត្រឹមថ្នាក់ទី៨សង្គម!។
កៈ ចាសកុង!
ខៈ
ហ្នឹងហើយកាលនឹងនៅក្នុងថ្នាក់ទី៨នៅឯសង្គមចាស់!នឹងហើយក្រោយមកនឹងខ្ញុំនឹងបានរស់ពេញវ័យនឹងហើយនឹងខ្ញុំនឹងក៏បានចេះនឹងអាចជួយធ្វើការងារឪពុកម្តាយខ្លះនឹងកាលនឹងខ្ញុំនឹងក៏បានឈប់រៀននឹងចឹងហើយអឺ!...ខ្ញុំនឹងក៏បានទៅជួយធ្វើការងារឪពុកម្តាយ!
កៈ ចាស!
ខៈ ដល់ពេលអាយុបាន១៩ឆ្នាំខ្ញុំ
បានជួបប្រទះនឹងសង្គ្រាមនៅក្នុងសម័យ១៨មិនាឆ្នាំ១៩៧០នឹងណា!។
កៈ ចាស!

ខះ ហ្នឹងហើយ! ពេលនោះនៅក្នុងថ្ងៃទី១៦ ខែ៤នៅក្នុងឆ្នាំមួយពាន់អើយ! ឆ្នាំ១៩៧០អី!នៅក្នុង១៩៦៩នឹងខ្ញុំក៏បានរៀបអាពាហ៍ពិពាហ៍ បានមានក្រុមគ្រួសារមួយ!។
ក:ចាស!
ខះ មានប្រពន្ធនឹងគាត់មានឈ្មោះថា អែ គឹមអើន រស់នៅក្នុងភូមិឃុំនឹងជាមួយណា!។
ក: ចាសកុង!
ខះ ក្រោយមកក៏បានបង្កើតកូន បាន៣នាក់អី!...ចំនួនបាន២នាក់។ ២នាក់នឹងមានប្រុស បាន២ ប្រុស១នឹងមានឈ្មោះថា ជាសុផុន ហើយនឹងកូនមួយទៀតនឹងមានឈ្មោះថា ជា អ៊ឹម នឹងហើយ! ចឹងមកដល់ពេលសម័យឥឡូវនឹងគេបានមានគ្រួសារ ទាំងអស់គ្នានឹងហើយ!ចឹងបានរៀបកូនទាំង២នាក់នឹងរួចទៅហើយ!កូនរបស់ណា!។
ក: ចាសកុង!
ខះ ហើយខ្ញុំ រហូតបានមានចៅ។
ក: ចាសកុង!
ខះ រហូតបានមានចៅ៣ទៅ៤នាក់ ហើយចៅ បានឡើងដល់៥នឹងនាក់។
ក: នឹងហើយ!
ខះហើយខ្ញុំនឹងមានអាយុបាន៦៩ឆ្នាំនឹងហើយនេះមិនជាធម្មតានោះទេនេះ!។
ក: អូ!ហើយចុះកុងកើតនៅក្នុងឆ្នាំណាដែរ?
ខះ កើតនឹងនៅក្នុងឆ្នាំ១៩៥០នេះអត្តសញ្ញាណប័ត្រ!
ក: មាននៅក្នុងអត្តសញ្ញាណប័ត្រដែរកុង?
ខះ នៅក្នុងអត្តសញ្ញាណប័ត្រនេះ!នៅក្នុងឆ្នាំ១៩៥០ណា!។
ក: នៅក្នុងថ្ងៃខែណាដែលកុង?
ខះ កើតនៅក្នុងថ្ងៃទី៦ខែ៤ឆ្នាំ១៩៥០គត់។
ក: អូ!...ចុះចន្ទគតិ ឆ្នាំចន្ទគតិវិញ?
ខះ ខ្ញុំបានភ្លេចបាត់ទៅហើយ!
ក: ចុះឆ្នាំសត្វណាកុងឆ្នាំខ្មែររបស់យើងដូចជាឆ្នាំជូត ឆ្នាំឆ្លូវ ខាល ថោះ!..បាទៗ!។
ខះ កើតនៅក្នុងឆ្នាំថោះបាទ!។
ក: ចឹងឈ្មោះរបស់កុងនឹងគឺបានត្រូវជាមួយនឹងអត្តសញ្ញាណប័ត្រអីនឹងដែរឬទេ?
ខះ ត្រូវតើ ត្រូវទាំងអស់! កាលនឹងគេបានដាក់ឈ្មោះនឹងថាជាអឿនឹង ! ខ្ញុំនឹងត្រូវទៅយកអត្តសញ្ញាណប័ត្រដែរឬទេ?បើសិនជាត្រូវការនឹងខ្ញុំនឹងទៅយកអោយ?
ក: ចាស!កុនអត់អីនោះទេចាំហើយចាំ...
ខះ
ហើយចឹងដល់ពេលដែលខ្ញុំបានមានក្រុមគ្រួសារចឹងទៅកាលនឹងនុងនៅក្នុងសម័យសង្គ្រាមនៅក្នុងឆ្នាំ១៨មិនាឆ្នាំ១៩៧០ហ្នឹងកាលនឹងខ្ញុំបាននៅបំរើការងារនៅឯមូលដ្ឋាននិងបានច្រើនសន្ទប់អីចឹងទៅ!។
ក: ហឹ!...
ខះ
ហ្នឹងហើយ!រហូតបានជាគេបានរំដោះនៅថ្ងៃទី៧មករាអី!...រំដោះអី...រំដោះពេល១៧មេសាហ្នឹង!ចឹងកាលនឹងខ្ញុំហ្នឹងបានរស់នៅជាមួយនិងគ្រួសារ ទាំងត្រដងដែរ ព្រោះអីនោះកាលនុង ខ្ញុំ
វាអត់បានធ្វើការងារអីនោះទេ!គ្មានគេហៅថាចំនេះវិជ្ជាអីហ្នឹង!
បានខ្ពស់ខ្ពង់នោះទេ
បានធ្វើស្រែអីជាធម្មតា!ជាកសិករអីជាធម្មតាអីនឹងចឹងទៅណា!។
ក: ចាសកុង!

ខៈ ហ្នឹងហើយ!
ចឹងបានដល់ពេលនៅក្នុងឆ្នាំអឺ!...នៅក្រោយពេល១៧មេសាបានធ្វើការនៅក្នុងសហករនឹងវាបាន
ជួរជត់នឹងបានគ្រាប់សារពើអីនឹងចឹងទៅ!ចឹងតែបានរស់រានអីនឹងបានមានជីវិតនឹងហើយតែកាលនឹងបានរស់នឹងទាំងត្រដនឹងរស់ដោយត្រដកំសត់ក្រពេក។
កៈហឺ!...
ខៈ
ហ្នឹងហើយដល់ពេលក្រោយមកនឹងបានយើងនឹងចេះតែនិយាយទៅនឹងសង្ខេបៗទៅណា!
កៈ ចាសកុង!
ខៈ
ដល់ពេលបានមកដល់ក្នុងពេលរដូវកាលនៅក្នុងពេលគេបានរំដោះនៅសម័យ៧មកភាបានមកហើយហ្នឹង!ខ្ញុំនិងក៏គ្មានមុខរបរអីដែរគ្រាន់តែ
បានធ្វើស្រែអីជាធម្មតា
និងគេចាត់តាំងអោយខ្ញុំបានធ្វើជាប្រធានគណៈកម្មាធិការអាចារ្យនៅឯវត្តក្រាំងនៅឯភូមិពារុំ នៅក្នុងឃុំពារុំនៅឯខេត្តព្រៃវែងនឹងរហូតបានដល់១៧ឯនោះ។
កៈ អូ!...
ខៈ បាទ!កាលនឹងខ្ញុំនឹងបានធ្វើជាគណៈកម្មាធិការវត្តនឹងណា!។
កៈ ចាសកុង!
ខៈ
ហ្នឹងហើយ!ហើយដល់ពេលក្រោយនឹងបានមកទៀតខ្ញុំបានមកលេងលោកនៅឯកុតនឹងនៅឯកុតហង្សនៅឯវត្តសង្រ្កានព្រះព្រហ្មនៅឯស្ទឹងមានជ័យយើង
ហើយលោកក៏បានមកសួរដល់ខ្ញុំនឹងដែរថាញោម!
ញោមឯងបានមកហើយចឹងមិនបាចទៅឯភូមិនឹងវិញនោះទេនៅឯទីនេះចឹងទៅ!នៅជាមួយនិងអាត្មានៅឯនឹងចឹងទៅ!ហើយចឹង
ខ្ញុំក៏បានមកនៅជាមួយនិងព្រះសង្ឃ
ទៅបានជាធម្មតាចឹង!ហើយបានបំរើព្រះសង្ឃអីនឹងបានខ្លះចឹងទៅបានទៅធ្វើជាអាចារ្យបុណ្យនឹងអាចារ្យអីបានសព្វគ្រប់នៅឯទីក្រុងភ្នំពេញហ្នឹងណា!។
កៈ ចាស!
ខៈ
បានជួយធ្វើកិច្ចការរបស់លោកអីខ្លះចឹងទៅបានបំរើព្រះសង្ឃអីតាំងពីពេលនុងមកចឹងទៅ!។
កៈ ចាស!
ខៈ ហើយចឹងមកដល់ពេលសម័យឥឡូវនឹងនៅឯវត្តសង្រ្កាន្តតាព្រហ្មស្ទឹងមានជ័យក៏បានចាត់តាំងអោយខ្ញុំហ្នឹងធ្វើអឺ!..ជាសមាជិតគណៈកម្មាធិការនៅឯវត្តសង្រ្កាន្តតាព្រហ្មស្ទឹងមានជ័យនឹងបានបន្ថែមទៀត។
កៈ ចាសកុង!
ខៈ ហើយខ្ញុំបានគេចពីខាងនោះ ហើយក៏បានមកជួបខាងនេះចឹងទៀតន៎។
កៈ ហឺស!...
ខៈហ្នឹងហើយបានថាខ្ញុំនិងបានជួបតែ បុណ្យនិងបានជួបតែល្អ។
កៈ ចាស!
ខៈ ហើយដល់ពេលសម័យឥឡូវនេះ
បច្ចុប្បន្នកាលនឹងដល់មកដល់ពេលសព្វថ្ងៃនេះកូនចៅរបស់ខ្ញុំបានរស់នៅជីវៈភាព បានសមរម្យ
ជាធម្មតាដូចជាវាមិនបានមានពេកហើយក៏មិនបានខ្សត់ពេក។គេហៅថាសមរម្យណា!។
កៈ ចាសកុង!

ខះហ្នឹងហើយ!ដូចផ្ទះរបស់ខ្ញុំមាន២សំរាប់អោយកូននៅហើយ!
ហើយខ្ញុំបានធ្វើកន្លែងសំរាប់អោយយាយរបស់ខ្ញុំនឹងនៅហើយ!
អោយគាត់នឹងនៅកន្លែងដែលស្អាតបាទ!
ដាក់ប្រដាប់ប្រដាលអោយដល់គាត់អោយបានមួយកំផ្លេរអីចឹងទៅ!ព្រោះអីខ្ញុំវានៅឯទីនេះហើយចំណែកឯគាត់គឺនៅឯស្រុក។
កះ ចាស!
ខះ បាទ!គឺយើងបាននៅដោយខ្លួនដោយឡែកពីគ្នាណាកូន!។
កះ ចាសកុង!
ខះ
បាទនឹងហើយបានថាអ្វីទាំងឡាយការតស៊ូនៅក្នុងឆាកជីវិតរបស់ខ្ញុំនឹងវាដូចត់នៅកសិករពីកន្លងទៅនៅពីស្រុកពីភូមិនឹងបានជួបការលំបាកវាច្រើនក្រាស់ក្រៃលប៉ុន្តែមកដល់ពេលបច្ចុប្បន្នកាលនឹងមកនៅឯកន្លែងនឹងគ្រាន់តែថានៅក្នុង១ខែខ្ញុំអាចរកថវិការបានក្នុង៥០ម៉ឺនទៅ៦០ម៉ឺននៅក្នុង១ខែចឹងណា!។
កះ ចាស!
ខះ
បាទចិញ្ចឹមជីវិតបាន!ហេតុអ្វីបានថាខ្ញុំអាចរកចិញ្ចឹមជីវិតបាននឹងព្រោះអីពុទ្ធបរិស័ទគាត់ត្រូវការខ្ញុំបើសិនជាព្រះសង្ឃគាត់ត្រូវការគុតលេខ១២ គុតលេខ១៣ឬក៏គុតលេខ១៤ត្រុវការខ្ញុំលោកថាញ៉ោមទៅផ្ទះរបស់អាគ្មាសង់ផ្ទះគេបុណ្យបច្ច័យបួនគេឬក៏បុណ្យអែអី!...សូត្រមង់ឡើងផ្ទះអីចឹងទៅណា!សង្ឃទានអីចឹងទៅ!ខ្ញុំចេះតែទៅៗទៅដល់យើងបានធ្វើកិច្ចនឹងអោយដល់គេហើយចឹងទៅជួនកាលទៅប្រជាពលរដ្ឋខ្លះនឹងនៅដល់ពោធិចិនតុនអីនឹងគាត់បានថាហី!អ៊ុំអើយខ្ញុំរកអញ្ជើញអ៊ុំឯងទៅធ្វើពិធីក្រុងពាលីសូមទឹកសូមដីព្រោះអីខ្ញុំបានសងលំនៅស្ថានថ្មី ទើបតែបុកគ្រិះសាងសង់អីចឹងណា!។
កះ ចាសកុង!
ខះ
ហ្នឹងហើយចឹងខ្ញុំក៏បានទៅជួយគេចឹងទៅ!ជួនកាលទៅគេបានជូនដល់ខ្ញុំបាន១០០ដុល្លាអីនឹងក៏មានដែរកូន តាំងពីមកនៅទីនេះ!បាទ!
ជូន៤០០០០រៀលក៏មានជូន២០០០០រៀលក៏មានជូន១០ម៉ឺនក៏មាន២០ម៉ឺនក៏មាន៤០ម៉ឺនក៏មានដែរ។
កះ ចាស!
ខះ ទៅតាមលទ្ធិភាពរបស់គេ។
កះ ទៅតាមសទ្ធារបស់គេ។
ខះ បាទទៅតាមសទ្ធាជ្រះថ្លារបស់គេចឹងទៅបានថា
អ្វីទាំងឡាយនៅក្នុងការតស៊ូរបស់មនុស្សយើងម្នាក់ៗលុះត្រាតែ...កូនឯងក៏ដោយខ្ញុំក៏ដោយបើសិននរណាមានកូនបានពូនជាចៅហើយត្រូវបណ្តុះបណ្តាលធូរជានអោយចេះអោយដឹងអោយស្គាល់គុណស្គាល់ទោសចឹងណា!
កះ ចាស!
ខះ ហ្នឹងហើយ!កុំធ្វើអ្វីបំពាន់នៅផ្លូវខុសច្បាប់ស្អីក៏ដោយសុទ្ធ!
សូម្បីតែខ្ញុំម្នាក់ឯងហ្នឹងចាស់ប៉ុណ្ណឹងហើយក៏យើងត្រូវមានទិសដៅ១សំខាន់សំរាប់ដាស់តឿនក្រែរំលឹកដល់កូនៗចៅៗជំនាន់ក្រោយថាអ្វីដែរល្អហើយអ្វីដែរអាក្រក់ចឹងណា!ហ្នឹងហើយយើងត្រូវតែដាស់តឿនហើយអីជាពិសេសភ្ញៀវហើយមានពុទ្ធបរិស័ទរបស់លោកដែលមានបគៈជនមកពីទីជិតឆ្ងាយចឹងត្រូវតែបដិសណ្ឋារៈ
ទោះបីជាអ្នកឯងមានឬអ្នកឯងក្រខ្ញុំអត់ដឹងនោះទេប៉ុន្តែអោយតែថាមកដល់កន្លែងយើង! គឺយើងត្រូវតែបដិសណ្ឋារៈជាមួយ។
កះ ស្វាគមន៍!ចាសបដិសណ្ឋារកិច្ច។
ខះ បដិសណ្ឋារកិច្ចជាមួយ!។
កះ ចាស!

ខៈ ស្វាគមន៍ជាមួយហើយថាពូអញ្ជើញទៅណា មីងអញ្ជើញតៅណា
ឯកឧត្តមអញ្ជើញទៅណា អ៊ុំអញ្ជើញទៅណាចឹងទៅ!
និយាយចឹងទៅហើយដល់ពេលយើងគេមើលឃើញ!មានគេមើលឃើញយើងដូចថា
គេថា
អូ!អ៊ុំឬពូនេះគាត់អាចសមរម្យអាចនឹងអញ្ជើញទៅធ្វើកិច្ចអីនៅផ្ទះរបស់យើងនឹង
បានចឹងគេនឹងអញ្ជើញយើងទៅហើយ។
កៈ ចាសកុង!
ខៈ នឹងហើយ!
កៈ ចុះកុងមកនៅទីនេះបានរយៈពេលប៉ុន្មានឆ្នាំហើយ?
ខៈ ខ្ញុំមកនៅទីនេះបានរយៈពេល
មិនបាននៅចាំថ្ងៃនោះទេប៉ុន្តែនៅក្នុងឆ្នាំ២០១២។
កៈ អូ!...
ខៈ ហ្នឹងហើយ!មករហូតដល់ឥឡូវនេះនឹងបាន២០១៨ហើយ!(សើច)
កៈ ចាស!៦ឆ្នាំហើយកុង!
ខៈ
បាទ!មកដល់ឥឡូវនេះការងារសំខាន់ណាកូន!កូនឯងហ្នឹងក៏ដោយខ្ញុំសុខចិត្តនិ
យាយលេងជាមួយនឹងក្មេងៗដែរគេហៅថាការដាស់តឿនអប់រំ
ដាស់តឿនគ្រែរំលឹក។(និយាយរឿងផ្សេង!) សុភាសិតនិយាយថា
"អ្វីៗនៅក្នុងលោកតែងកើតដោយព្រោះហេតុឃើញច្បាស់ក្រឡេកគុណម៉ែឪ
កូនរស់ធំឡើងកូនត្រូវរកផ្លូវសងគុណម៉ែឪទើបត្រូវច្បាប់"ពាក្យនេះណាជាពាក្យ
ប្រដៅរបស់អ្នកប្រាជ្ញ។
កៈចាសកុង!
ខៈ "បើសិនជាមិនសងអីជាធំដុំ កុំតែស្រីមុំប្រែក្រឡាប់
រត់ចេញពីផ្ទះមិនបានប្រាប់ប្រញាប់តាមប្រុសព្រោះស្នេហា" អាហ្នឹងសំរាប់កូនស្រី។
កៈ អានឹងសុភាសិតអីគេដែរ?
ខៈ សុភាសិតលោកអី!...ឈិន កាន
គាត់បានសរសេរទុកនៅក្នុងសៀវភៅមួយសំរាប់អោយយើងបានមកដើម្បីនឹងប
ដិបត្តិមកក្រោយៗណា!
កៈ ចាស!
ខៈ ឯសុភាសិតទី២" ចំណែកកូនប្រុសក៏ដូចគ្នាកុំធ្វើឬកពាក្មេងបាតផ្សារ
ប្រគល់ខ្លួនអោយស្រីស្រាគ្រែផ្កាតសង្ខាចោលម៉ែឪ"។
កៈ ហ្នឹង!
ខៈ អាពាក្យហ្នឹងសុទ្ធតែជាពាក្យល្អៗដូចនេះយើងត្រូវចេះផ្សព្វផ្សាយ!
តែសំរាប់បុគ្គលខ្លះដែរគាត់មិនបានចាប់អារម្មណ៍គាត់ថាហឺ!ស្អីគេមានស្តីអោយអ
ញចេសចុះ!អីសព្វគ្រាប់នឹង!តែបើសិនជាពិតទៅបើសិនជាយើងយកវាទៅពិចារ
ណានោះគឺល្អណាស់កូនណា!
កៈ ចាសកុង!
ខៈ ហ្នឹង!ចឹងបានថាអ្វីទាំងឡាយយើងធ្វើតែល្អ!!
ស្អីក៏ដោយអោយតែល្អវាមិនចេះចាញ់នោះទេដូចជាមាសទឹក១០ចឹងមិនខ្លាចភ្លើ
ងដែរចាស់បុរាណលោកថាណាកូន!
កៈ ហ្នឹងហើយកុង!
ខៈ
អ្វីក៏ដោយអោយតែថាយើងធ្វើតែអំពើល្អថ្ងៃណាមួយអំពើល្អអាចតាមយើងរហូតឯ
អំពើបាបវិញមិនបានប៉ុន្មាននោះទេកុងតែបានជួប។
កៈ ចាស!
ចុះកុងបងប្អូនរបស់កុនវិញគាត់មានប៉ុន្មាននាក់ដែរសំរាប់សមាជិកក្រុមគ្រួសារ?

ខះបងប្អូនរបស់ខ្ញុំមានឈ្មោះ៧នាក់ទី១ឈ្មោះជាទូច ភេទស្រី ទី២ ជា ជរ ភេទប្រុស ទី៣ ជា ឈួន ភេទប្រុស ទី៤ ជាសុខ ភេទស្រី ទី៥ជា ជឿន ភេទប្រុស ទី៦ ជា អឿង អឺ!...ជាមឿនភេទស្រី ទី៧គឺខ្ញុំនឹងហេហ៎! ។
កះ ចាសចឹងកុងកូនពៅគេ!
ខះ បាទឈ្មោះ ជា អឿ។
កះ ជាកូនទី៧។
ខះ បាទខ្ញុំគឺកូនពៅគេគឺខ្ញុំហើយ!
ហើយចឹងបានខ្ញុំថាកូនស្រីអើយរស់នៅភូមិរបស់ខ្ញុំឈ្មោះថា ឃុំក្រៃ នៅក្នុងភូមិក្រាំង ឃុំព្រៃសន្លឹក នៅក្នុងស្រុកពារាំង នៅក្នុងខេត្តព្រៃវែង នេះមិនមែនជាធម្មតានោះទេវាជួជត់ណាស់!ស្រុកនោះកាលពីដើមក្រណាស់ម្ដាយរបស់ខ្ញុំនឹងគាត់បានអនិច្ចកម្មតាំងពីនៅក្នុងឆ្នាំមួយពាន់ប្រាំងបួនរយសិតសិបបួន(១៩៧៤)ទំលាក់គ្រប់បែបមិនទែនគាត់បានស្លាប់ទៅ។
កះហឺ!...
ខះ ឪពុករបស់ខ្ញុំនឹងគាត់បានស្លាប់ នៅក្រោយម្ដាយរបស់ខ្ញុំបាន១ឆ្នាំនៅក្នុងឆ្នាំ១៩៧៥អូ!កាលនឹងនៅក្នុងឆ្នាំមួយពាន់ប្រាំងបួនរយសិតសិបបួន(១៩៧៤)នឹងដូចតែគ្នានោះទេកាលនុងប៉ុន្មានវានៅចុងឆ្នាំ។
កះ ចាស!
ខះ វានៅក្នុងឆ្នាំតែមួយនឹងណា!លោរតែគាត់បានស្លាប់អស់ អារម្មណ៍បានជាប់ជិតដាមជាមួយនឹងគាត់ព្រោះអីពេលគាត់បានស្លាប់ទៅអត់បានធ្វើបុណ្យអីអោយគាត់នៅពេលជំនាន់នោះ!
កំពុងតែជាប់សង្គ្រាមយ៉ាងជូរជត់ នឹងហើយ!
ហើយមកដល់ពេលបច្ចុប្បន្នកាលនេះមិនមែនថាយើងនឹងមិនមានគំនិតអីនោះទេគ្រាន់តែថាឥឡូវនេះនឹងសភាពកាលនៅក្នុងប្រទេសដឹកនាំដោយរាជរដ្ឋាភិបាលគាត់បានផ្សព្វផ្សាយថាជៀកអ្នកច្បាប់និយាយថាជៀកហើយអ្នកនោះនិយាយថាចុះ និយាយអីនិយាយទៅចុះគឺ ខ្ញុំមិនដឹងនោះទេ!
ព្រោះអីខ្ញុំជាប្រជាពលរដ្ឋសាញ្ញាមបំពេញតែកាព្វកិច្ចជាពលរដ្ឋនោះទេ។
កះចាស!
ខះ
បំពេញកាព្វកិច្ចអីនឹងក៏ចឹងទៅ!ប៉ុន្តែបើសិនជាបើខ្ញុំមើលទៅឃើញខុសដល់ពេលថ្ងៃអនាគតបោះឆ្នោតវិញខ្ញុំត្រូវបោះអោយនរណាក៏បានស្រាចតែចិត្តរបស់ខ្ញុំ។
កះ
ចាស!ចុះបងប្អូនរបស់កុងវិញតើកុងបានចង់ចាំអ្វីគេខ្លះដែរនៅក្នុងសាច់រឿងរបស់កុងជាមួយនឹងពួកគាត់កាលកុងនៅពីកុមារភាព?
ខះ
បាទ!បងប្អូនរបស់ខ្ញុំនឹងណាកូនស្រីមិនមែនធម្មតានោះទេមិននិយាយតែពូជពង្សត្រកូលនោះទេគ្រាន់តែខ្សែជីវិត បងប្អូនកូនចៅម្ដាយខ្ញុំ ឪពុករបស់ខ្ញុំឈ្មោះ រស់ ជាហើយ ម្ដាយខ្ញុំឈ្មោះ ឡុង ខ្ញុំរស់នៅក្នុងភូមិក្រាំង ឃុំព្រៃសន្លឹក នៅក្នុងស្រុកពារាំង នៅក្នុងខេត្តព្រៃវែង
នឹងមានបងប្អូន៨នាក់នឹងជួបផលលំបាករហូត។ ម្ដាយរបស់ខ្ញុំនឹងគឺក្រណាស់សសរ...អឺ រផ្ទះរបស់គាត់នៅលើផ្ទឹមផ្ទះនឹងគាត់បានសរសេរដាក់ជំពាក់ លិមហួរប្រាំងរយរៀល( ៥០០៛)។
កះ ហឺ!...
ខះ ជំពាក់ឈួន ហ៊ាងហួរពីររយរៀល( ២០០៛) នៅឯរផ្ទះនឹងណា!
កះ ហឺ!...
ខះ គាត់បានអនិច្ចកម្មហើយនៅក្នុងឆ្នាំ១៨មិនា១៩៧០ហើយក៏នៅតែជំពាក់គេ!
កះ ហឺ!...

ខះគាត់ក្រណាស់កូន!
ក្រណាស់នៅពេលខ្លះទឹកខែស្រកទៅបបរក្តួចលាយជាមួយអង្គអោយកូនស៊ីណំលាយពោតលាយអី។
កះ ចាស!
ខះ នឹងហើយ ជូរចត់ណាស់!។
កះ
ចុះកុងវិញកាលនៅពីក្មេងៗនឹងតើកុងចូលចិត្តលេងល្បែងអីគេខ្លះជាមួយពួកគាត់កាលនៅក្មេង?
ខះ ខ្ញុំហេស៎?
កះចាស!
ខះ ខ្ញុំហេស៎កាលនៅក្មេងខ្ញុំវាខ្វៀលក្របីខ្វៀលគោ
ខ្ញុំបានលេងតែជាមួយក្របីនឹងគោ។
ខ្វៀលក្របីនឹងចាំគោចឹងបានលេងតែចាំក្របីអីជាមួយគ្នា
បងប្អូនរបស់ខ្ញុំជាធម្មតាអត់ដែរចេះឈ្លោះគ្នា!សំរាប់បងប្អូនរបស់ខ្ញុំ៦ទៅ៧នាក់នឹងគឺអត់មានដែរទៅឈ្លោះគ្នាចឹងគឺអត់ចេះឈ្លោះគ្នានោះទេ។
កះ ចាស!
ខះ
បាទអត់ដែលចេះឈ្លោះគ្នានោះទេ។លេងតែល្បែងចង់ធ្វើ...ក្រវង់តែដីឥដ្ឋនឹងទៅធ្វើជាម៉ាស៊ីនភ្លើងអី។
កះជារូបសូនអី!
ខះ
អត់នោះទេ!ធ្វើតែម៉ាស៊ីនភ្លើងនឹងអារូបស្អី!ៗអាពីដើមនឹងអាគុយគេវិញចឹង!(សើច)ធ្វើគ្រឿងមេក្រូអី!
គេបានដាក់មេក្រូធ្វើជាប្រគល់លុនដីឥដ្ឋអីសំរាប់ធ្វើអីចឹងណា!
កះ ចាស!ៗ
ខះ (គាត់ផ្ទាក់គេបានមកចាក់ពីក្រោយ)
កះ (សើច)!
ចាស!កុងហើយទាក់ទងមកដល់ពេលឥឡូវនឹងតើបងប្អូនរបស់កុងយ៉ាងម៉េចហើយ?
ខះ នៅសល់តែ២នាក់ហ្នឹង។
កះ ចាស!
ខះ បងប្អូនរបស់ខ្ញុំនឹងគឺបានស្លាប់អស់នៅសម័យពពត មើលស្លាប់បង សុខមួយ បងទូចមួយ បងភឿនមួយបានស្លាប់អស់៣នាក់! ដល់មកបងជា
ជរនឹងគាត់បានទឹមតែស្លាប់ក្រោយនឹងនោះទេ!ទឹមតែបានស្លាប់៣ឆ្នាំនឹងនៅក្នុងឆ្នាំនឹងនោះទេណា!។
កះ ចាស!
ខះ ៣នាក់នឹងស្លាប់នៅក្នុងសង្គ្រាម
បងថ្លៃក៏បានស្លាប់នៅក្នុងសង្គ្រាម!អស់ច្រើនហើយប្អូនថ្លៃរបស់ខ្ញុំនឹងក៏ស្លាប់នៅក្នុងសង្គ្រាមនេះមានរូបថតនៅក្នុងគុកទួលស្លែងដែរតើ! ។
កះហឺ!...
ខះ
បាទ!រូបរបស់ប្អូនរបស់ខ្ញុំវាបានធ្វើជាទាហានហើយបានស្លាប់នៅគុកទួលស្លែងនឹងបានថា វាជូរចត់ប៉ុន្តែការតស៊ូរបស់ប្រជាពលរដ្ឋខ្មែររបស់គ្រួសាររបស់ខ្ញុំ!
ខ្ញុំដាច់ខាតត្រូវតែតស៊ូអោយទាល់តែបាន
ទោះបីជាខ្ញុំត្រូវឡើងត្នោតខ្ញុំទិញអី!...ខ្ញុំបានរែកដីជីកដំឡូងអីសំរាប់ដូរស្រូវត្រីសំរាប់នឹងចិញ្ចឹមកូនប្រពន្ធនឹងមាតាបិតាម៉េចនឹងក៏ខ្ញុំមិនដែលទៅពាក់ពាល់អីអោយទាក់ចិត្តជាមួយនឹងគេនោះទេ មិនចេះអត់នោះទេ។

កៈ ចាស!
ខៈ ខ្ញុំអត់អោយអត់នោះទេ។
កៈ
ចាសកុង!ហើយមកដល់ពេលឥឡូវនេះនឹងតើពួកគាត់នៅឯណាហើយគាត់បាន
ប្រកបមុខរបរអ្វីខ្លះដែរកុង?
ខៈ អូ!...បងរបស់ខ្ញុំមានឈ្មោះថា ជា ជឿននឹងគឺលីថានៅឯនេះ នៅច្បារអំពៅ
នៅពេលសព្វថ្ងៃនេះនឹងគឺគាត់កំពុងតែស៊ីឈ្នួលគេធ្វើសំណង់ហើយចំណែកឯបង
ប្រុសម្នាក់ទៀតមានឈ្មោះថា ជា ជួន ប្រុសដែរនោះភូមិយុគ ឃុំសចាន់
នៅក្នុងស្រុកពារាំង នៅក្នុងខេត្តព្រៃវែងប៉ុន្មានគាត់ចាស់ណាស់ទៅហើយ!។
កៈ ចាស!
ខៈ អាយុ៨២ឆ្នាំហើយណា!។
កៈ ចាស!
ខៈ
ប្រពន្ធរបស់គាត់ក៏ចាស់ណាស់ដែលអាយុចិតសិបប្រាំងបួនឆ្នាំ(៧៩ឆ្នាំ)គាត់ប៉ែត
សិបពីរឆ្នាំ(៨២ឆ្នាំ)នៅរស់មកដល់បច្ចុប្បន្នប៉ុន្តែខ្ញុំនឹងណា!កូនខ្ញុំសព្វថ្ងៃសព្វថ្ងៃ
នេះនឹងខ្ញុំបានថាអាសំអុនអើយឯងអោយអង្គដល់អ៊ុំ ជួនឯងនឹង១គៅ
កន្លះគៅទៅជួយចិញ្ចឹមបងព្រោះអីគាត់ក្រ។
គាត់នៅក្រដដែលរហូតមកដល់សព្វថ្ងៃនេះនឹង! គាត់ចាស់។
កៈ គាត់មានឈ្មោះអ្វីដែរកុង?
ខៈ ជា ជួន!
កៈ ចាសគាត់មានធ្វើអ្វីដែរអី!..
ខៈ ពីណា?គាត់មានឈ្មោះជា ជួនត្រូវជាបងរបស់ខ្ញុំ។
កៈ តែគាត់មានប្រកបការងារអ្វីដែរ?
ខៈ
គាត់ចាស់ណាស់ទៅហើយ!គាត់គឺជាកសិករដែរប៉ុន្តែគាត់នឹងវាបានចាស់ទៅនឹង
ណាកូន។
កៈចាស!ចុះអី!...
ខៈ មានអីនោះទេកូនរបស់ខ្ញុំបានចិញ្ចឹមមករហូត!
កៈ នឹងហើយកុង!
ខៈ នឹងហើយ!
កៈ
ចុះកុងចំពោះឪពុកម្តាយរបស់កុងវិញតើកុងដឹងថាគាត់នៅឆ្នាំណាហើយពួកគាត់
បានកើតនៅឯណាដែរឬទេកុង?
ខៈ គាត់បានកើតនៅ ព្រៃសន្លឹក ភូមិព្រៃសន្លឹក ឃុំព្រៃសន្លឹក នៅក្នុងស្រុកពារាំង
នៅក្នុងខេត្តព្រៃវែងម្តាយ ហើយឪពុករបស់ខ្ញុំឈ្មោះរស់ជានឹង
កើតនៅក្នុងភូមិយោក ឃុំមេសព្រះចាន់
ខេត្តព្រៃវែងជាមួយនឹងគ្នាគេតែបានខុសភូមិនិងឃុំ
តែស្រុកនិងខេត្តជាមួយគ្នា។
កៈ ចាសកុង!
ខៈ
ប៉ុន្តែសំរាប់ថាគាត់កើតនៅឆ្នាំណានឹងខ្ញុំមិនបានដឹងនោះទេវាយូរណាស់ទៅហើយ
។
កៈ ចុះកុងកាលនឹងគាត់បានចិញ្ចឹមជីវិតដោយអីគេដែរកាលនុង?
ខៈគាត់ធ្វើតែស្រែរហូតនឹងណាកូន។
កៈ ទាំង២នាក់តែម្តង?
ខៈ បាទ!
កៈ ចាស!

ខ៖
ឪពុករបស់ខ្ញុំនឹងគាត់ធ្វើស្រែដល់ពេលដែលគាត់បានទំនេរទៅគាត់បានធ្វើចង្អេរធ្វើជាតៅអីសំរាប់លក់។
ក៖ អូ!...
ខ៖ ចាស់បុរាណណា!
ក៖ ពូកែណាស់!
ខ៖ នឹងហើយ!
ក៖ កាលនុងគាត់ចេះដោយខ្លួនឯងឬក៏បានចេះតពីជីដូននឹងជីតាមក?
ខ៖ គាត់បានចេះដោយខ្លួន ឯងនឹងតែម្តង។គាត់នឹងហើយ!។
ក៖ អូ!...
ខ៖ ហើយដល់ពេលបងប្អូនរបស់ខ្ញុំពូជតាសុខនឹងយាយណៃអឺ! ពូជតាកែរ
យាយហួន អឺយ!យាយហួស!ភ្លេចបាត់ទោះហើយ!!!
ក៖ ចឹងកុងតើពួកគាត់ជាមនុស្សបែបណាដែរឪពុកម្តាយរបស់កុង?
ខ៖ អូ!...ឪពុកម្តាយរបស់ខ្ញុំនឹងគាត់គឺជាអាចារ្យវត្តនឹងដែរ។ គាត់ស្លូតបាទ!
គាត់មិនចេះមានរឿងរាវអីជាមួយនឹងអ្នកស្រុកនោះទេ។
ក៖ ចាស!
ខ៖ កាលនុសនឹងណា!
ក៖ ចាស!
ខ៖
អត់មានអីនោះទេកូន!អ្វីនឹងខ្ញុំបានដឹងថាអ្វីដែរខ្ញុំដឹងជាងគេនឹងនៅពេលដែលខ្ញុំបានធំដឹងក្តីឡើងគឺខ្ញុំមានអារម្មណ៏ថាអើយ!ម្តាយរបស់ខ្ញុំជំពាក់ ថៃហួរជំពាក់លីមហួរចំនួនប្រាំងរយរៀល(៥០០៛)នៅលើផ្ទើរផ្ទះហើយជំពាក់ឈួន ហ៊ាងចិនលក់ស្រាលក់ទំនិញនៅនឹងក្នុងទូបគេនឹងចំនួនប្រាំងរយរៀល(២០០៛)។
ក៖ ចុះបានសងគេរួចឬនៅកុង?
ខ៖ សងខ្ញុំជាអ្នកសងណា!
ក៖ ចឹងកុងជាអ្នកដែលសងជំនួស?
ខ៖
បាទ!ខ្ញុំសងអោយគេរួចរាល់ហើយព្រោះខ្ញុំខ្លាចម្តាយរបស់ខ្ញុំគាត់ទូលទ្រព្យរបស់គេកូន។
ក៖ចាស!
ខ៖ ចឹងហើយសងអោយរួចអត់អីនោះទេ!
ក៖
ចឹងកុងបានធ្លាប់លឺគាត់បានប្រាប់កុងអ្វីខ្លះអំពីជីវិតរបស់គាត់កាលនៅក្មេងៗ?
ខ៖ គាត់បានប្រាប់ថាកូនអើយ!
បើនិយាយទៅកាលនុងគាត់បានមើលឃើញខ្ញុំកាន់ច្រពាមបាញ់សត្វបាញ់អីនឹងណា!ចឹងគាត់ថាដាច់ខាតកុំបាញ់សត្វ
ទី២កុំអោយចាប់សត្វលលកយកទៅដាក់នៅក្នុងទ្រូងចិញ្ចឹមនោះទេ
ទី៣មិនអោយយកសត្វអីផ្សេងៗទៅចិញ្ចឹមនោះទេ
យកទៅដាក់នៅក្នុងទ្រុងចិញ្ចឹមនោះទេគ្រែលោរ
ដូចថាយើងនឹងមានកម្មពារជាមួយនឹងសត្វចឹងគ្រែលោរគេបានចាប់យើងដាក់នៅក្នុងគុកដូចដែលយើងដាក់លលកនៅក្នុងទ្រុងដែលមិនអោយលេងនោះទេ!
មិនចឹងហេស់ណាស់! មិនអោយលេងនោះទេ
ដល់ពេលក្រោយមកនឹងខ្ញុំបានគោរពតាមមាតាបិតារបស់ខ្ញុំ។
ខ្ញុំបាន...មុននឹងខ្ញុំបានមកនៅឯទីក្រុងភ្នំពេញមុខឆ្នាំ២០០៨ដល់២០០៩គេបានហៅខ្ញុំអោយមករៀននៅសាលានេះ...នៅឯសាលាអើយ!...នេះសីហនុរាជនេះគេមករៀនវិបាតអាចារ្យខ្មែរ
ខ្ញុំបានមករៀនមានសញ្ញាណប័ត្រអាចារ្យដែលបាទ!កាលនុងនោះ។

ក៖
ចាសកុង!ចុះជីដូននឹងជីតារបស់លោកតាវិញគាត់មានឈ្មោះអ្វីដែរទាំងខាងឪពុកនិងខាងម្តាយរបស់កុង?
ខ៖ ជីតារបស់ខ្ញុំមានឈ្មោះថា តាឡុង យាយ អ៊ុក នឹងជាជីតាខាងម្តាយណា។
ក៖ ចាស!
ខ៖ហើយអឺ!...ខាងឪពុកមានឈ្មោះថា តារស់ និងយាយ លាប់។
ក៖ ហឹស!
ខ៖ នឹងហើយ!
ក៖ ចុះលោកតាមាននៅចង់ចាំថាគាត់បានកើតនៅឯទីណានៅក្នុងឆ្នាំណាដែរ?
ខ៖ អូ!មិនទាន់នោះទេកូន។
ក៖ គ្រែលោរឪពុកម្តាយរបស់លោកតាបានប្រាប់ចឹងណា?
ខ៖ អត់នោះទេមិនបានចាំទេកូន! កើតនោះគាត់បានកើតតាំងពីឆ្នាំហូស!!...
ក៖ យូរណាស់ហើយ!
ខ៖បាទ!
ក៖ ហើយចុះលោកតាមានកើតទាន់ពួកគាត់ដែរឬទេ?
ខ៖ អត់ទាន់នោះទេ! កើតអឺនឹងទាន់ជីតារបស់ខ្ញុំគាត់ស្លាប់បាត់ទៅអស់ហើយ។
ក៖ ចុះលោកតាមាននៅដឹងរឿងអីគេខ្លះជាមួយនឹងពួកគាត់ដែរឬទេ?
ខ៖
គ្មានបានដឹងរឿងអីនោះទេ!គ្រាន់តែថាក្រុមគ្រួសារត្រកូលគ្រួសាររបស់ខ្ញុំនឹងដូចថាមិនដែរមានរឿងអីនោះទេដូចថាស្លូតបូតអឺនឹងជាធម្មតាចឹងទៅ!ប៉ុន្តែចំនុចសំខាន់នឹងគឺគាត់បានជឿទៅលើផ្លូវរបស់ព្រះសាមាសាពុទ្ធច្រើនពេក!!
ច្រើនណាស់ដែលគាត់បានជឿហ៎ មិនសុខចិត្តអត់មាត់
គាត់សុខចិត្តយកបាយ១វែកសណ្តែក១គួរដើម្បីយកទៅប្រគេនដល់លោក
ដាច់ខាតគឺមិនខាននោះទេគាត់ជឿណាស់។
ក៖ ចាស!
ខ៖ បាទ!
ក៖ ចឹងក្រុមគ្រួសាររបស់កុងនៅក្នុងខេត្តនុងបានយូរប៉ុណ្ណាដែរ?
ខ៖ អូ!...តាំងពីដើមមកតាំងពីនៅក្នុងឆ្នាំ១៩១០ឬក៏១៩១២ម៉េះយ៉ាង។
ក៖ ចាស!
ខ៖ រស់នៅ! មួយអាយុសកាលមកនឹងរស់នៅឯទីនុងមិនបានទៅឯណាផង។
ក៖ ទឹមតែពេលចូលសម័យអាពតបាន បានកុងរស់នៅបែកគ្នាចឹងណេស់?
ខ៖
ក្រោយពីអាពតបានមកទៀតបានខ្ញុំបានរស់នៅជាមួយនឹងគ្នានុងព្រោះអឺបងប្អូនខ្ញុំនុងបានរស់នៅជាមួយគ្នាទាំងអស់ក្រោយមកទៀតនឹងបងជាជឿននឹងដែលខ្ញុំបានប្រាប់ថាគាត់រស់នៅឯច្បារអំពៅហ្នឹង។
ក៖ចាស!
ខ៖ គាត់បានទៅនៅឯ សឿ
នៅឯសឿអឺ!...នៅឯខេត្តបាត់ដំបងណា!បានមួយគ្រួសាររបស់គាត់នឹងបាននៅចឹងទៅ! ដល់ពេលសង្គ្រាមបានចប់១៧មេសា ៧៥នឹងគាត់បានមកស្រុកវិញ។
ក៖ ចាស!
ខ៖ នុងហើយ!
ក៖ហើយកុងមានបងប្អូនសាច់ញាតិនៅខាងក្រៅប្រទេសដែរឬទេ?
ខ៖ អត់មានផង!បាទ!
ក៖
ចុះកាលពីកុងបានរៀបអាពាហ៍ពិពាហ៍វិញកាលនុងកុងបានស្រលាញ់គ្នាឬក៏ឪពុកម្តាយគាត់ជាអ្នកដែលទុកដាក់អោយ។

ខះ មានមាតាបិតារបស់ខ្ញុំគាត់ក៏ត្រូវខ្ញុំក៏ត្រូវបាទ!
ចូលស្តីដណ្តឹងទុកបាន១ខែទៅ៣ខែបានបានរៀបអាពាហ៍ពិពាហ៍។
ក: កាលនុងកុងបានរៀបអាពាហ៍ពិពាហ៍នុងនោះពេលណាដែរ?
ខះ
ខ្ញុំបានរៀបអាពាហ៍ពិពាហ៍នឹងខ្ញុំវាបានភ្លេចឆ្នាំប៉ុន្តែណែកអី!...ភ្លេចថ្ងៃប៉ុន្តែខែខែផល្គុន ខែផល្គុនណែកនៅក្នុងឆ្នាំ១៩៦៩ ខ្ញុំបានរៀបការ។
ក: ចាស!
ខះ
រៀបហើយប្រហែលជាបាន៤ខែកើតសង្គ្រាម១៨មិនានៅក្នុងឆ្នាំ១៩៧០!នឹងហើយខ្ញុំបានរៀប។
ក: នៅឆ្នាំ១៩៧០កុង?
ខះបាទ!នៅ១៩៧០នឹងខ្ញុំបានមានកូនពោះធំអាបងគេនឹងហើយ!
មកដល់ពេលឥឡូវនឹងអាបងនឹងមានអាយុបាន៥០ឆ្នាំហើយ!(សើច)។
ក:
ចាស!កុងអាចប្រាប់ដល់ខ្ញុំបានដែរឬទេថាពេលមុនដំបូងកុងបានជួបនឹងលោកយាយប្រពន្ធរបស់កុងនៅពេលណាដែរ?
ខះ
ខ្ញុំអីណែកជួប!...បានមកជួប...ខ្ញុំបានស្រលាញ់គ្រួសាររបស់ខ្ញុំនឹងកាលនុងយើងនៅស្រុកស្រែនឹងជាធម្មតាជាកសិករ
កំពុងតែបំពេញការងារបង្កបង្កើតផលដកស្ទូងអី!
ចំរូតនៅខែច្រូតខែអី!ទៅយកប៉ះ
ប្រវាសដៃគ្នាច្រូតដូចថាស្រែរបស់កូនឯងទៅវេល១៥នាក់ហើយស្រែរបស់ខ្ញុំវេល២០នាក់ចឹងទៅ!
ដល់ពេលជួយរែកបាយរែកអីចឹងទៅយកទៅអោយវេលច្រូតវេលស្ទូងដកនឹងបានស្គាល់ចិត្តគ្នាទៅ។
ក:ចាសអូ!
ខះ ដល់ពេលស្គាល់ចិត្តគ្នាចឹងទៅក៏បាននិយាយប្រាប់ដល់ម្តាយរបស់ខ្ញុំ!
ហើយកាលនុងម្តាយរបស់ខ្ញុំនឹងគាត់ថា
ឯងនឹងទឹមតែអាយុបាន១៩ឆ្នាំចឹងទៅយកប្រពន្ធអី!
ចឹងខ្ញុំក៏ថាសិនជាខ្ញុំមិនយកនោះទេ
គេនឹងចាប់អោយខ្ញុំធ្វើជាទាហានឥឡូវហើយ!។
ក: ហឹស!!
ខះ ចឹងហើយខ្ញុំត្រូវយកគ្រួសារ!
ហើយគាត់ក៏បានទៅស្តីតាអែងយាយនួនត្រូវជាឪពុកម្តាយខាងប្រពន្ធរបស់ខ្ញុំនឹងណា!តាអែងនឹងយាយនួននឹងឪពុកម្តាយរបស់ប្រពន្ធរបស់ខ្ញុំនឹងហ៎នឹងហើយគាត់ទៅដណ្តឹងចឹងក៏គេបានអោយចឹងក៏បានជិញពិលាភសីចឹងទៅបានរៀបអាពាហ៍ពិពាហ៍កូនប្រុសស្រីចឹងទៅស្រីបានរៀបទៅ។
ក:ចាស!
ខះ
នុងហើយបានគ្នាចឹងទៅ!ហើយចំណែកឯខ្ញុំបុរសខ្ញុំម្នាក់នឹងណាកូនណែក!មានថ្ងៃថាំងនៅលើក្បាលមានសាក្សីនៅក្នុងវត្ត
មិនមែនមិនទាស់សោះនោះទេ!ខ្ញុំបានរៀបការជាមួយនឹងគ្រួសាររបស់ខ្ញុំនឹងតាំងពីឆ្នាំណែក១៩៦៩មកទល់បច្ចុប្បន្ននឹងមិនដឹងថាវាប៉ុន្មានឆ្នាំនោះទេណា!ប្រហែលជា៥០ឆ្នាំហើយនឹងមិនដឹង?
ប្រពន្ធរបស់ខ្ញុំនឹងបានស្រក់ទឹកភ្នែកដោយសារខ្ញុំនឹងតែម្តងនោះទេ!នឹងហើយ!
ក្រៅពីនឹងខ្ញុំមិនចឹងឈ្លោះគ្នាទៅអោយពីណាលីអត់ចេះសោះស្រក់ទឹកភ្នែកនឹងដោយសារលោកតាប្រធានភូមិនឹងគាត់លេងគាត់ថាគឹម

សឿនអើយ!អញបានឃើញអានោះវាជិះកង់ឌុមមនុស្សអាណាអានៃហ៎!
អត់ចូលផ្ទះទេអី! ពេលនឹងគាត់បានថាចឹងទៅ!
គាត់នោះសោត(សើច)គាត់ខ្លាចខ្ញុំនឹងទៅដើរលេងជាមួយស្រីជាមួយអី!(សើច)។
នៅជំនាន់នោះតែ១ដងនឹងកូនខ្ញុំបានអាណិតគ្រួសាររបស់ខ្ញុំនឹងមកដល់ពេលឥឡូវនឹង
ខ្ញុំមិនបានចេះឈ្លោះគ្នានោះទេរហូតបានដល់ខ្ញុំបានរៀបកូនរបស់ខ្ញុំបាន២នាក់នឹងណា! មានអាសំណុងនឹងអាអ៊ីមនឹងណា!ចឹងខ្ញុំប្រាប់ថាឯង
មិនបានទៅបុណ្យអីអោយអញក៏អត់ទៅ
តែដាច់ខាតមិនអោយប្រមាថប្រពន្ធនោះទេ! មិនអោយជេរ រពុទ្ធិពនដាលគ្នាគិះដៀលប្រពន្ធថាចេះថាចុសអីអត់បាននោះទេ
បើសិនជាលីដល់អញអត់បាននោះទេកូនឯងធ្វើយ៉ាងម៉េចក៏ដោយបើសិនជាមិនធ្វើបុណ្យអីអោយដល់អញ
ក៏មិនអោយលុយអីដល់អញចាយក៏បានដែលកុំអោយតែឯងនឹងទៅដៀលប្រពន្ធកុំអោយតែឯងនឹងទៅដៀលដាក់ប្រពន្ធទៅបានហើយ។
ក៖ ចាស!
ខ៖ អោយដូចឪ! ខ្ញុំបានប្រាប់ថាចឹងណា។
ក៖ ចាស!
ខ៖ អ្នកស្រុកជិតខាងណាកូន!គេកោតខ្ញុំថា
ហឺ!អានេះក្មេងសោះវាការមកដល់៤ទៅ១០
ទៅ២០ឆ្នាំវាមានកូនណានៃចឹងហើយវាមិនដែលបានមានលីសូរប្រកែកគ្នាមួយក្អឹសចឹងទៀត! ចឹងខ្ញុំវាអត់ចេះឈ្លោះនោះទេ
បើសិនណាជាខាងគ្រួសាររបស់ខ្ញុំនៅឯនឹង
ខ្ញុំហៅអោយមកជួបជាមួយនឹងកូនឯង។
ក៖ ចាស!
ខ៖ អត់ដែលឈ្លោះគ្នាសោះ!!
ក៖ ចាស!
ខ៖ ៥០ឆ្នាំកូនឯងគិតមើលគេអ្នកមាន គេអ្នកក្រ
គេអ្នកមធ្យមអីអីយ៉ាងណាក៏គេមានឈ្លោះគ្នាហើយចំណែកឯគ្រួសាររបស់ខ្ញុំអត់។
ក៖ ចាស!ចឹងមានសុភមង្គល។
ខ៖ បាទ! អត់មានដែលបានឈ្លោះគ្នានោះទេ។
ក៖ចាសកុង!ចឹងកាលនុងកុងស្រលាញ់លោកយាយដោយសារអីដែរកុង?
ខ៖ អឺម!
ខ្ញុំស្រលាញ់នឹងដោយសារតែខ្ញុំបានជួបពេលដែលរែកបាយជួយរែកអីនឹងនៅពេលស្ទូង ស្រែគាត់ហើយនឹងស្រែខ្ញុំនឹងគាត់ក៏បានទៅ!
ស្រែរបស់គាត់នឹងរវល់ចឹងខ្ញុំទៅហើយដល់ពេលស្រែរបស់ខ្ញុំដែលរវល់គាត់មកជួយគ្នាទៅវិញទៅមកចឹងណា!
ដល់ពេលហើយទៅក៏និយាយគ្នាស្តីអីទៅវិញទៅមកអីចឹងជាធម្មតាចឹងទៅ!ជាធម្មតានោះទេយើងប្រុសស្រី គេហៅថាធម្មជាតិកូន!!
ចេះនិយាយទាក់ទងគ្នាចឹងទៅក៏មានទឹកបាក់ចិត្តស្រលាញ់គ្នាចឹងទៅដល់ពេលរួចចឹងទៅក៏ម្តាយឪពុករបស់ខ្ញុំគាត់ក៏ស្តាប់
ព្រោះអីគាត់ស្រុះស្រួលគ្នាចឹងទៅក៏គេបានអោយ។
ក៖ ចឹងដោយសារតែលោកយាយគាត់ជាមនុស្សដែរល្អដែរ?
ខ៖ បាទ!ៗ
ក៖
ហើយលោកតាកាលនុងលោកតាបានរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរនៅកាលនុង?
ខ៖ បានត្រឹមថ្នាក់ទី៨ ។

កៈ នៅសាលាណាលោកតា?
ខៈ នៅឯសាលា រៀមជ័យ លោកគ្រូឈ្មោះអី!..លោកគ្រូ ឃោង លោកគ្រូ យ៉ាំង តាម៉ៅ គ្រូ យឹម គ្រូរ៉ែត ។
កៈ អូ!លោកតានៅចាំបានល្អមែនទែន។
ខៈ បាទ!
កៈ ហើយសាលាកាលនុងនៅតាមខេត្តហេស់លោកតា?
ខៈ នៅសាលាភូមិក្រាំង ឃុំព្រៃសន្លឹក នៅក្នុងស្រុកពារាំង នៅក្នុងខេត្តព្រៃវែងនឹងដដែរ។
កៈ ចាស! សាលា...
ខៈ ប៉ុន្តែកាលនុងមិនទាន់មានកង់ជិះនោះទេកូន! កាលនុងខ្ញុំបានដើរពីភូមិរបស់ខ្ញុំនឹងពីក្រាំងណាទៅសាលារៀនប្រហែលជា២គីឡូម៉ែត្រជាង ដើរទៅ។
កៈ ចាស!
ខៈ រត់ទៅហើយ! ដល់ពេលព្រលឹមឡើងលើកអាចម៍ក្របី អាចម៍គោហើយដល់ពេលព្រលឹមឡើង ក្តាប់បាយកកចឹងទៅហើយ។
កៈ ចាស!
ខៈ ស៊ុបណ្តើររត់បណ្តើរចឹងទៅហើយ។
កៈ
ចាសលោកតា!កាលនុងលោកតាអាចចេះសរសេរនឹងចេះអានបានល្អដែរឬទេសំរាប់ភាសាខ្មែរ?
ខៈ ខ្ញុំសរសេរបាន! បាទសំរាប់ភាសាបារាំងអីនឹងវាភ្លេចអស់ទៅហើយ។
កៈចឹងលោកតាអាចរៀនភាសាបារាំងនឹងបានត្រឹមប៉ុន្មានដែរ?
ខៈ អូ!ខ្ញុំបានរៀនភាសាបារាំងនឹងបានប៉ុន្មាននោះទេកាលនុងខ្ញុំចេះតែអ៊ី! អី! អ៊ុយអីនឹងខ្ញុំវាភ្លេចអស់ទៅហើយនឹង។
កៈ(សើច)
ខៈ ដោយសារខ្ញុំក្រណា។
កៈ ចាស!
ខៈ ចឹងទៅខ្ញុំវាមិនសូវជាបានគិតរៀនអំពីភាសានឹងគេ បើសិនជាអក្សរខ្មែរខ្ញុំចេះ អាចសរសេរ បានមើលបាន។
កៈចាស!
ខៈ បាទ!
កៈ កុងចឹងកាលនុង!
អី!...លោកតាបានមានមិត្តភក្តិស្និទ្ធស្នាលដែរឬទេកាលនៅជំនាន់នុងមកដល់ឥឡូវ?
ខៈ មាន!
កៈ គាត់មានឈ្មោះអ្វីគេខ្លះដែរទៅ?
ខៈ អាមួយនោះគេមានឈ្មោះ និត ហេន គេបានធ្វើជាឯឧត្តម មកដល់ពេលឥឡូវនេះ។
កៈ ហឺ!
ខៈបាទ! ១ទៀតចេក ចៀត ប៉ុន្តែកាលនុងហៅតែអា ខ្មៅៗនោះទេកាលនុងដែងចេក ចៀតនឹងណា នឹងហើយ!
នៅអើយ!បាននៅឯនុងហើយបាននៅចាំគោជាមួយនឹងគ្នាបាននៅចាំក្របីជាមួយនឹងគ្នា
ដល់មានគ្រួសារនឹងរាងៗខ្លួនចឹងអស់ទៅគេមកនៅឯភ្នំពេញចឹងទៅគេក៏បានមានគ្រួសារអីអស់ហើយគេមានធំដុំអស់ទៅ!
ក៏ខ្ញុំមិនទៅខ្វល់ខ្វាល់អីជាមួយនឹងគេនោះដែរ
ព្រោះអីយើងនឹងវាអត់ចឹងគិតតាមវាអត់ចឹងទៅ!

អត់មានទៅយកខ្ញុំទៅប្រៀបធៀបជាមួយនឹងគេនោះទេ
ប៉ុន្តែមិត្តភក្តិស្រលាញ់គ្នារាប់អានគ្នាទៅវិញទៅមកជាធម្មតា។
ក៖ ចឹងកាលនុងអី!...ក្នុងមានអនុស្សាវរីយ៍អីគេខ្លះជាមួយគាត់ជាមួយពួកគាត់?
ខ៖ ខ្ញុំមានអនុស្សាវរីយ៍អី! កាលពីដើមកូនអើយ! ស្មានេះជិះក្របីទៅផ្ទះ
ប្រហែលជាពីនេះទៅ១គីឡូហើយទៅសៀតកាំបិតពីនេះចឹងទៅ
ហើយនិយាយពីថាបានដើរទៅហើយមានដើមត្នោតរាប់ពាន់រាប់ម៉ឺនហើយវាផ្លែហ៊ី
ស!...ឡើងប៉ះស៊ីជាមួយនឹងគេនឹងជារៀងរាល់ថ្ងៃថាឯងប៉ះម្តងឡើងប៉ះត្នោតស៊ី។
ក៖(សើច)
ខ៖
ហ្នឹងហើយ!ចឹងទៅថ្ងៃខ្លះទៅ!ទៅរកត្រីទៅបាន៣ទៅ៤នាក់ចឹងទៅហើយជួនណា
ទៅបានបាញ់កង្កែបឆ្លុះកង្កែបពេលយប់ចឹងទៅណាកូន។
ក៖ ចាស!
ខ៖ នឹងហើយវាអនុស្សាវរីយ៍ជាមួយនឹងគ្នាដល់ពេលបានបែកហើយ!
រឿងថាកាលពីដើមនៅក្នុងជំនាន់របស់ខ្ញុំអាយុ១៥ឆ្នាំ ២០ឆ្នាំ ៣០ឆ្នាំ
គ្មាននរណាពីណាគេបានស្រវឹកការតែរែវដូចក្មេងនៅជំនាន់ឥឡូវនោះទេ។
ក៖ ហឹស!
ខ៖ នៅជំនាន់នោះគ្មានហ៊ាននោះទេកូន!
ពេលដែលបានឃើញព្រះសង្ឃឈរសុទ្ធតែអោន សុទ្ធតែឆ្វេក
ឃើញគ្រូណាកាលដែលខ្ញុំនៅរៀន!
ឃើញគ្រូដើរសុទ្ធតែអង្គុយ!ហើយគ្រូដល់ពេលដែលចេញពីសាលាគាត់គោះតុ
ផាំងហើយដើបមើលចេញទៅផ្ទះដើរនៅឯខាងស្តាំរហូត!ដល់មាប្រមូលម្នាក់ៗដើរ
ប៉ុន្មានក៏ដោយរត់ក៏ដោយក៏នៅតែប៉ុណ្ណឹង!
ក៏នៅតែអង្គុ(អោន)នឹងរហូតមិនដែលថាបានឃើញគ្រូហើយដើយនោះទេ បាទ!។
ក៖
ចឹងមកដល់ឥឡូវនឹងគឺពួកគាត់មានបានទាក់ទងជាមួយនឹងលោកតាដែលឬ
ទេសំរាប់មិត្តភក្តិស្និទ្ធស្នាលទាំងអស់នឹងណា។
ខ៖ នៅតើ!
ក៖ ចាស!
ខ៖ ឃើញចឹងនៅតែហៅខ្ញុំ! ម៉េចហាហ៎ហែង
ផឹកតែទឹកត្រពាំងងងុងនៅតែដដែលមកដល់អញផឹកតែទឹកសុទ្ធជិតងាប់ហើយ
អាហឹយ!។
ក៖(សើច)!
ខ៖ កើតរោគថ្លើម កើតទឹកនោមផ្អែម។
ក៖(សើច)!
ខ៖ ហើយគេនឹងបានបើទ្វារឡានរកជិះទៅនឹងណា។
ក៖ ចាស!
ខ៖ ហើយខ្ញុំនឹងអត់នោះទេ!ខ្ញុំថាហឹយ! បងអើយ!
កាលនុងគេអាយុស្រករគ្នានោះទេប៉ុន្តែខ្ញុំហៅគេថាបង! ព្រោះអីគេមានណា។
ក៖ ចាស!
ខ៖ អ្នកផឹកទឹកស្រះនៅទួលស្រឡៅ ទឹកបឹងត្រពាំងវាធម្មតានោះទេ!បងអើយ!
ហើយគាត់បានថាអញខ្លាចហែងហើយណា! អាយុរបស់ហែង!...ហែង៦៩ហេស៎!
ហើយខ្ញុំក៏ថាបាទ!ខ្ញុំ៦៩ហើយ! ហើយបងឯងប៉ុន្មានដែរ?
អញ៦៨ផងម៉េចទៅហេស៎!(សើច)។
ក៖ (សើច)!!ចាស!
ខ៖ ចឹងនៅតែរាប់អានគ្នាស្រលាញ់គ្នានឹងជាធម្មតា
ព្រោះអីទី១ទី២ខ្ញុំមិនដែលមានជំលោះអីជាមួយនឹងគេ!

ថាអ្នកដ៏ទៃចុះមិនដែលបានឈ្លោះហើយចុះប្រពន្ធរបស់ខ្ញុំទាល់មិនដែលបាន
ឈ្លោះដែរ! ខ្ញុំអត់ចេះឈ្លោះហើយកូនក៏ខ្ញុំមិនដែលគុំរាមនោះទេ!ខ្ញុំដឹងតែអឺ!...
កៈ ចាស!កូនរបស់កុងគឺបានរៀនសូត្រទាំងអស់គ្នាអស់ហើយកុនហ៎?
ខៈ បាទ!ចៅរបស់ខ្ញុំបានបរិញ្ញាណប័ត្រទាំងអស់គ្នាហើយ។
កៈ ហឺ!ល្អមែនទែន!
ខៈ កូនរបស់ខ្ញុំរៀនបានឌីប្លូម
អឺ!អាដែងណែកបាក់ឌុបមួយនាក់ហើយអាម្នាក់ទៀតត្រឹមថ្នាក់ទី១០បានគេឈ
ប់ដោយសារកាលនុងពេលឈឺណា! អានុងស្ពាយដែល
បើសិនជាមួយទៀតនឹងវាបានប្រឡងបាក់ឌុបនឹងជាប់ហើយវាបានដាក់ពាក្យប្រ
ឡងធ្វើជាគ្រូ! ចឹងពេលនោះវាប្រឡងអត់ជាប់ចឹងក៏វាឈប់ទៅ(សើច)។
កៈ ចាស!កុងចឹងកាលពីមុនកុងបានធ្លាប់ធ្វើស្រែចំការត្រូវទេកុង?
ខៈ បាទ!ខ្ញុំធ្វើស្រែចំការនឹងរហូត។
កៈ ចាស!ចឹងគ្រួសាររបស់កុងគឺជាកសិករ?
ខៈ បាទ!ជាកសិករពេញតែម្តង។
កៈ
ចាស!ចឹងជីវិតរបស់កុងតាំងពីពេលមុនមកកុងមានការងារធ្វើអ្វីខ្លះដែរដើម្បីចិ
ញ្ចឹមជីវិតដើម្បីនឹងរកកំរៃចិញ្ចឹមខ្លួន?
ខៈ កាលនុងកូន!
ពេលរដូវកាលធ្វើស្រែខ្ញុំបានធ្វើស្រែដល់ពេលផុតរដូវការធ្វើស្រែវាវីងរាំងខ្ញុំកាប់អុជ
ដឹកយកទៅលក់អោយចិន។
បាន១ដឹក៥០រៀលកាលនឹងដឹកលក់អោយណា!ដើម្បីយកលុយកំរៃនឹងដូចថាពេល
ដែលកូនឯរវល់បុណ្យហើយបានប្រាប់ដល់ខ្ញុំចឹងក៏ខ្ញុំទៅចូលទៅ!
មាន១០រៀលទៅ២០រៀលចឹងកូនឯងចឹង!
ហើយពេលចៅឯមានរវល់ការកូនប្អូនអីដែរគេបានមកហៅចឹងក៏ចង់ដៃគេទៅ!
បានតែមុខរបរក្រៅៗនឹង មានរកត្រីអីខ្លះទៅ
ឡើងត្នោតទៀតណ៎ខ្ញុំពូកែទៀតណ៎អារឿងឡើងត្នោត។(សើច)
កៈ ចាស!
ខៈ បាទ!
កៈ រហូតមកដល់ពេលកុងចាស់ទៅបានឈប់?
ខៈ
បាទ!ដល់ពេលចាស់ទៅនឹងគេបានអោយខ្ញុំធ្វើជាគណៈកម្មាធិការវត្តនៅក្នុងវត្ត
សង្រាន្តតាព្រហ្មស្ទឹងមានជ័យ នៅភ្នំពេញនឹង!
ហើយនោះខ្ញុំបានឈប់ទៅសម្លាប់ត្រីអីហើយនោះតាំងពីអាយុបាន៤៥ឆ្នាំនឹងខ្ញុំ
ឈប់សម្លាប់សត្វអីមួយក៏ខ្ញុំមិនសម្លាប់នោះដែរ។
កៈ ចាស!
ខៈ មូលហេតុដែលខ្ញុំមិនសម្លាប់ចៅឯងបានដឹងដែរឬទេ?
កៈ កម្មពារឬក៏បាបហេស៎កុង?
ខៈ មូលហេតុដែលខ្ញុំមិនសម្លាប់នៅពេលរដូវកាលបិណ្ឌ! បិណ្ឌភ្ជុំនឹងណា។
កៈ  ចាស!
ខៈ វេនរបស់ខ្ញុំនឹងណាដែលត្រូវជាបិណ្ឌទី៧។
កៈ ចាស!
ខៈ ហើយទៅយាយរបស់ខ្ញុំនឹងណាគាត់បានថា ណែកពុកអុនហាស៎
ហើយខ្ញុំឆ្លើយថា ហើយចឹយនុង?
ហ៊ុស្មាហ្នឹងហើយ!គេប្រកាត់ភ្លើងឡើងពេញភូមិហើយនុះ! វេនយើងនឹងណាវេនទី៧
ចុះកាលនុងត្រូវធ្វើម្ហូបទៅវត្តនោះ!។
តោះចុះទៅរកអីមកបបរចាប់មាន់មកខ្ញុំនឹងក៏ចុះទៅ
ដូចមាត់ថាចឹងខ្ញុំនឹងក៏ចុះទៅអត់មានពិលទេកាលនុងមានតែពិលនឹងដែកកេ

សនឹងចង្កៀងឃ្លូររបស់យើងណ៎!កេសដែកកេសលីឡើងផែស!
ឃើញមាន់នឹងកំពុងតែដេកកឡើងចឹង!នៅជិតភ្លីនោះ
ថាចាប់វាធ្វើបបរដាក់បិណ្ឌព្រោះអីជាវេនរបស់យើង។
ក៖ ហឺ!
ខ៖ដល់ពេលបានឃើញចឹងខ្ញុំក៏យកចង្អូលដៃរបស់ខ្ញុំទៅ!...
ក៖ ប៉ះ!
ខ៖
ប៉ះទ្រូងមាន់!វាងកក្បាលមកនឹងងាកមករកមើលយើងថាអូ!...ខ្ញុំនឹងមានធម៌ពិចារណាថា អញ!ចាប់គេយកទៅសម្លាប់ឥឡូវនេះហើយយកទៅធ្វើបុណ្យ
អាម៉េចស្មានតែអញបានបុណ្យហេស៎ គ្នាកំពុងតែដេកស្រួលណ៎!!
ក៖ នឹងហើយ!
ខ៖ ទៅចាប់គ្នាឡើងខ្មោកយកទៅធ្វើ! ហើយខ្ញុំអត់នោះទេ
គ្រាន់តែមាន់នឹងងាកមករកខ្ញុំចឹងខ្ញុំរកឡើងជិះកង់របស់ខ្ញុំនឹងឡើងរឹងទៅផ្ទះ
ហើយពេលនឹងអត់បានប្រាប់ដល់យាយខ្ញុំទៀត!
ខ្ញុំក៏ទៅផ្ទះគេធ្វើជ្រូកផ្ទះតាមីយាយអេង។
ក៖ ហឺ!
ខ៖ កាលនុងគាត់នៅឆ្ងាយពីភូមិប្រហែលជា១គីឡូហ៎! ក៏បានជិះទៅទាំងយប់!
ពេលដែលបានជិះទៅដល់ តាមីគាត់ថា អែងហាស!
អាវែងវាមករកអីនឹងអានឹងវាមិនដែរមកនោះទេ!។
ក៖ (សើច)!
ខ៖ គាត់បានសួរដល់ប្រពន្ធរបស់គាត់ហើយចឹងខ្ញុំក៏ថាហូស៎!
កុងហាស៎ខ្ញុំនៅក្នុងថ្ងៃនេះគ្មានអីបបរទៅវត្តទេបើថាមាននៅសល់កន្លះគីឡូ
២ទៅ៣ខាំអីអញ្ជើញចែកមកលោកអើយ!!!ខ្ញុំមិនដឹងថាទៅរកឯណានោះទេស្មាននឹងហើយ! ហឺ!អេងឯងមើលមានដែរទេនុះហ៎?
មានអីសាច់ជ្រូករបស់គេសុទ្ធតែប្រកាន់ម្នាក់១គីឡូកន្លះ ២គីឡូ
គេយកអស់ហើយ!អត់មាននោះទេ!
ខ្ញុំក៏ថាបើសិនជាគ្មានក៏អត់ទៅតា!គាត់ក៏ថាអត់ទេ អេងមើលសាច់វាធ្វើ!
អាឈ្លួលវាធ្វើនៅសល់នឹងអោយទៅអាវែងទៅហ៎!
កាលនុងតានឹងគាត់ហៅខ្ញុំនឹងថាអាវែងកាលនុង។
ក៖ ហឺ!
ខ៖
ដល់ចឹងកាលនឹងគាត់ក៏បានអោយសាច់ជ្រូកនឹងមកដល់ខ្ញុំចឹងទៅ!ហើយខ្ញុំអោយលុយអត់រាប់ទៀត កាលនុងអោយ១៥រៀលកាលនុងណា!។
ក៖ ចាស!
ខ៖ អត់រាប់នោះទៀត! ថាយកទៅនោះអេងអោយទៅ!
ហើយចឹងកាលនុងហូស!...ខ្ញុំប្រញ៉ាប់ជិះកង់មក!
ពេលដែលបានមកដល់យាយថាហឺ!ដាស់តាំងពីយូរហើយមិនទាន់បានស្ទីផង!ខ្ញុំដាក់ដាំទឹកបានពុះហើយមិនទាន់មានសាច់!
ហើយខ្ញុំក៏ថាសាច់ជ្រូកមានហើយកុំមាត់ហើយចឹងគាត់ក៏ចិញ្ច្រឹមដាក់នៅក្នុងបបរទៅ។
ក៖ ចាស!
ខ៖
រួចហើយបានយកទៅវត្តនឹងហើយអស់ហើយកូនអើយ!បាននៅពេលថ្ងៃត្រង់រួចរាល់ឆ្លងវេនបិណ្ឌរបស់យើងនឹងណា!ហើយខ្ញុំក៏ថាហឺ!...
ម៉ាក់អូនអើយខ្ញុំសូមទោសណា!ដោយសារមិនបានទាន់ពេលវេលាវារៀងនៅយូរបន្តិចនោះដល់សារតែខ្ញុំនៅអាណិតមាន់! ខ្ញុំអត់ចាប់មាន់នោះទេ
ពេលខ្ញុំទៅចាប់ទ្រូងរបស់វានឹងវាងកកត្រដាងស្លាបមកមើលខ្ញុំឡើងត្រលូៗ!ហើយ

ចឹងខ្ញុំក៏ថាហឺ!គ្នាស្លាប់ឥឡូវហើយចឹងហើយខ្ញុំមិនធ្វើនោះទេក៏ខ្ញុំជិះទៅទិញសាច់ជ្រូកនៅតាមីយាយអែងឯនុសហើយគាត់បានថាងាប់!ខ្លួនឯងជិះកង់រហូតទៅដល់នុង?(សើច)
ក៖ ចាស!
ខ៖ នុងហើយ!
ក៖ ចាស!តាំងពីនុងមកបានធ្វើអោយតាសម្រេចចិត្តទៅកាន់សីលចឹងទៅ?
ខ៖
នុងហើយ!ខ្ញុំឈប់សម្លាប់សត្វរហូត!ខ្ញុំបានចូលវត្តហើយគេបានអោយខ្ញុំធ្វើគណៈកម្មាធិការវត្ត១៧ឆ្នាំនៅវត្តក្រាំងនុង។
ក៖
ចាស!ចឹងតាចឹងនៅក្នុងជីវិតរបស់លោកតាតាំងពីក្មេងមកនឹងតើលោកតាមានជីវិតផ្លាស់ប្តូរអីគេខ្លះដែរនៅក្នុងជីវិតរបស់លោកតា?
ខ៖ បាទ!បានផ្លាស់ប្តូរមូលហេតុអ្វីបានផ្លាស់ប្តូរ!
ផ្លាស់ប្តូរនូវចំនុចម៉េញនោះកាលពីដើមឡើយនឹងខ្ញុំសម្លាប់ខ្ញុំកូស
ខ្ញុំបានផឹកស្រាខ្ញុំបានដើរលេងអីចឹងតិចតួចចឹងណា!
មិនមែនទៅកោងកាចនោះទេ ប៉ុន្តែធម្មតាទេ
ពេលដែលគេបានចាក់ស្រាមកចឹងនៅពេលដែលគេមានរវល់ខ្មោចងាប់អីណា!អង្គុយនៅជុំគ្នាអីចឹងក៏បានផឹក១កែវទៅ២កែវអីចឹងទៅ!គេក៏មិនចេះលាក់នោះដែរនិយាយទៅត្រង់ចឹងតែម្តងទៅ!មកដល់ពេលឥឡូវនេះនឹងគឺខ្ញុំកែល!
អាអ្វីទាំងឡាយដែលបានខុសដែលគេបានហៅថាទិសដៅ
នឹងទ្រឹស្តីរបស់ព្រះសាមាសាពុទ្ធជាអ្នកប្រាជ្ញ
បានដាស់តឿនអោយបានដើរតាមផ្លូវល្អ
ខ្ញុំក៏ដើរតាមហើយអ្វីដែលខុសនោះខ្ញុំមិនទៅចង់អោយមានបុណ្យស័កអីប៉ុន្នានក៏ខ្ញុំមិនទៅដែលបាទ!(សើច)។
ក៖ ចាសកុង!
ខ៖
គេថាមនុស្សបានជឿពេកនឹងងាប់អីងាប់នឹងនុងចឹងណា!ចឹងបើសិនជាខ្ញុំសិនអោយងាប់នឹងសីលនុងចុះ!(សើច)។
ក៖
កុងចឹងកាលពីសម័យមុនហើយមកដល់ពេលសម័យឥឡូវនឹងគឺកុងចូលចិត្តមុខម្ហូបអីគេដែលទៅកុងសំរាប់ពិសា?
ខ៖ ខ្ញុំហេស៎?
ក៖ ចាស!
ខ៖ បើសិនជាខ្ញុំវិញស្អីក៏ដោយមិនចេះប្រកែកទេ! ព្រោះអីវាបានឆ្លងកាត់វាឆ្អែត!ថាហែងចង់កង្កែបអាំង កង្កែបដុត ឆៅយ៉ាងម៉េចក៏ខ្ញុំត្រូវដែរ
ដូចថាមានត្រីប៉ុណ្ណាត្រីក្រពត់ប៉ុណ្ណាសាច់ជ្រូក សាច់មាន់
សាច់គោបានប៉ុណ្ណានឹងគឺខ្ញុំអត់មានរើសនោះទេ!
ថាអារឿងមុខអីក៏ស៊ីដែរប៉ុន្តែមិនចេះមាត់កនោះទេចេះតែស៊ីទៅថាវាឆ្ងាញ់នឹងមិនឆ្ងាញ់ក៏វាជារឿងធម្មតាចេះតែស៊ីទៅ! បាទ!អត់មានរើសនោះទេ។
ក៖ ហឹម!
ចុះចំពោះល្បែងវិញកាលនៅកុមារភាពវិញតើកុងចូលចិត្តលេងល្បែងអ្វីខ្លះដែរ?
ខ៖ មិនលឺខ្ញុំថាធ្វើមេក្រូ?
ក៖អូ!តែប៉ុណ្ណឹងនោះទេណ៎?
ខ៖
បាទ!ធ្វើមេក្រូអីចឹងអោយតែថាគេមានអីចឹងធ្វើអានឹងហើយធ្វើដូចជារហាតទឹកជាន។
ក៖ ចុះសំរាប់បទចម្រៀងវិញលោកតា?

ខៈ
បទចម្រៀងខ្ញុំកាលនៅជាសិស្សសាលាខ្ញុំមានរៀនច្រៀងអីនឹងបានសព្វគ្រប់ដែរ។
កៈ ឈ្មោះអីគេដែរលោកតា?
ខៈ បាទ?
កៈ កាលនុងមានបទអីគេខ្លះដែរ?
ខៈ បទចម្រៀងស៊ីន
ស៊ីសាមុតនឹងខ្វះអីខ្ញុំចេះកគោកនឹង!តែមកដល់ពេលឥឡូវនេះខ្ញុំចាស់ហើយចឹង
ខ្ញុំភ្លេចហើយ។
កៈ (សើច)!
ខៈ មែនតើ!
ខ្ញុំចាស់ហើយខ្ញុំភ្លេច!ខ្ញុំបានធ្លាប់ច្រៀងនៅជាមួយច្រៀងតជាមួយគេអីនឹងចឹង
ដែរនុង។
កៈ
អូ!ហើយលោកតាអី!ដូចជាមកដល់ពេលឥឡូវនេះនឹងលោកតានៅតែស្តាប់ដែរតើ
ហេស់លោកតា?
ខៈ នូវ!នូវតែបានស្តាប់ចឹងបទភ្លេងការភ្លេងអី។
កៈ ចាស!ចុះបទសម័យវិញតើលោកតាមានចូលចិត្តស្តាប់ដែរឬអត់?
ខៈ ឥឡូវនេះខ្ញុំចង់សិក្សាបន្ថែមខ្ញុំចង់សិក្សាធ្វើអាចារ្យ
ពិលាការនឹងទៀតព្រោះអីខ្ញុំបានធ្លាប់នៅស្រុក!ខ្ញុំបានការគេបានប្រហែលជា២០
០គូអីចឹងដែរណា។
កៈ ហ្នឹងហើយលោកតា។
ខៈ
មកដល់ពេលឥឡូវនេះខ្ញុំចង់រៀនបន្ថែមទៀតរៀននៅឯភ្នំពេញរៀបចំការនៅភ្នំ
ពេញព្រោះអីបានរៀបចំការនៅឯភ្នំពេញនឹងបានចំនួន២រោង!ណា។
កៈ ចាស!
ខៈ មកដល់ពេលឥឡូវនេះចឹងយាយចង់បន្ថែមទ្រឹស្តីនឹងទៀត!
យើងចូលចង់ស្ពានមានមេត្រីពីកូនរបស់គេដែល
គេបានរៀបអាពាហៈវេហៈនឹងណា! ឈ្មោះថា
វេហៈនឹងវិវាហៈនឹងវាមានឈ្មោះខុសភ្លែកពីគ្នាមានពាក្យពីរមាត់ចឹងណា!ចឹងបាន
បានខ្ញុំបាទ!ទាំង៣បានឡើងមកនេះមកតាមសំអាងផ្លូវស្រីសូមអោយលោកមេ
បាប្រឡោមមើលរូបឆោមរោមពណ៌ខាងស្រី គុណសប្បុសចរិយា មាយាទ កំពស់
ក្នុងនាមយើងទាំង៣នាក់នឹងចូលមកនិយាយស្តីការជាមួយនឹងលោកមេបាឯង
ចឹងបើសិនជាមិនសមរម្យចឹងទៅ!...តាមដំណើរចឹងទៅណាយើងចង់រៀនអោយវា
បន្ថែមទៀតអោយពាក្យណាដែលវាល្អ!!ចឹងណា។
កៈ ចាស!ដែលជាទំនៀមទំលាប់របស់ខ្មែរយើងពីមុនមក?
ខៈ
បាទ!ជាទំនៀមទំលាប់របស់ខ្មែរយើងបើសិនជាមិនជាទំនៀមទំលាប់របស់ខ្មែរ
នោះគឺអត់នោះទេ!ទោះស្អីក៏ដោយណា!
កៈ
ចាសហើយចឹងលោកតាអី!...សមាជិកនឹងបងប្អូនក្រុមគ្រួសារអីលោកតាតើមាន
នរណាគេដែលគាត់ចេះលេងឧបករណ៍ភ្លេង?
ខៈ បងប្អូនរបស់ខ្ញុំហេស?
កៈ ចាស!
ខៈ គ្មាននោះទេបើសិនជាគិតអោយសព្វទៅៗ!អត់មាននោះទេ
បើសិនជាពូជបងជរក៏គ្មានបងទូច
ក៏គ្មាន!គ្រាន់តែថាវាដើរលេងរាំច្រៀងអីជាមួយនឹងគេអីចឹងកូនរបស់គាត់ណា!

ដែលថាអោយបានមានចូលទៅរៀននៅឯក្នុងក្រុមភ្លេងជាមួយនឹងគេអីនោះគឺគ្មាននោះទេ។
ក៖
អូ!...លោកតាចុះសំរាប់ផ្ទះរបស់លោកតាវិញកាលនៅក្នុងសម័យពេលលោកតានៅកាលពីតូចៗកាលនុងមានលក្ខណៈយ៉ាងម៉េចដែរលោកតា?
ខ៖ ផ្ទះរបស់ខ្ញុំកាលនៅរស់ពីឆ្នាំ១៩៦៩មកទល់ឆ្នាំ១៩៨៨
ដល់៨៩នោះណ៎កាលនុងខ្ញុំបាននៅផ្ទះសសរឬស្សីអីខ្លះ!សរសឈើអីខ្លះហើយនឹងសរសរស្តៅណាស់ឬស្សី!។
ក៖ចាស!
ខ៖
ហើយមកដល់នៅក្នុងឆ្នាំ១៩៨៩នុង!ខ្ញុំបានឡើងទៅឯក្រចេះទៅទិញឈើទិញអីទៅបានធ្វើផ្ទះអំនុងហើយ!នៅក្នុងឆ្នាំ១៩៨៩នឹងហើយកាលនុងខ្ញុំបានធ្វើផ្ទះធំហើយបានធ្វើសរសរ១២ហើយមកដល់គល្លូវនឹងសរសបាន២០បាទ!
សរស២០ហើយផ្ទះនឹងហើយនឹងមានបន្ទប់ក្រោមនុងខ្ញុំបានរៀបគន្លកាវ៉ូអីរៀបថ្មអីអោយដល់យាយរបស់ខ្ញុំអោយបានស្អាតព្រោះអីគាត់គឺចាស់ណាស់ហើយ!
អោយគាត់បាននៅអោយស្រួលអោយមានកង្ហា១នៅខាងលើ។
ក៖ ចាស!ៗ
ខ៖
មានទូមានកន្លែង១អីចឹងស្អីៗសព្វគ្រប់របស់គាត់អោយដល់គាត់បានមួយសំលាញ់ចុះរបស់គាត់ព្រោះអីគាត់នៅឯក្នុងស្រុកណាកូន។
ក៖ ចាស!
ខ៖ បាទ!ឧបត្ថមអោយគាត់អោយបានគ្រាប់ព្រោះអីគាត់បានចាស់ហើយណា!
ចឹងមានបច្ច័យដែលខ្ញុំបានអោយពីខាងនឹងចឹងទៅវា!
ឧទ្បាហរណ៍ថានៅក្នុង១ខែខ្ញុំបាន៦០ម៉ឺនទៅ៧០ម៉ឺនរៀលចឹងអោយទៅដល់យាយឯងព្រោះអីថាយាយឯងចាស់ណាស់ទៅហើយ!ចឹងហើយយាយឯងទទួលទានទៅសំពត់ស្លៀកអីយកទៅអោយបានម៉ាសំលាញ់ស្អីក៏ដោយស្រាប់តែចិត្តកុំខ្លាចក្រែណាខ្ញុំរអ៊ូថាយាយឯងចេះចុះកុំខ្លាច!ហើយនៅកន្លែងនេះខ្ញុំបានទិញការ៉ូពីខាងចំការដូងទៅអោយឡានដឹកទៅយកទៅរៀបនៅឯងខាងចេះមានទទឹងចេះមានបណ្តោយបាន៦ម៉ែត្រ៧ទឹកស្អាតហើយខ្ញុំដាក់ស្អី!មានភ្លើងអីម៉ាសំលាញ់អោយគាត់ម៉ាគ្រាប់។(សើច)
ក៖(សើច)!ចាសកុង!
ខ៖ អាណិតគាត់ព្រោះអីគាត់ចាស់ហើយចំណែកឯកូនៗគេនៅឯនោះចឹងក៏បានធ្វើស្អាតអោយដល់គាត់ហាស់ហើយបន្ទប់ទឹកដាក់នៅក្បែរនុងមានបន្ទប់ទឹកធ្វើអស់ជាងមួយពាន់ដុល្លា(១០០០ដុល្លា)ដែលហើយនឹងមានការធ្វើបន្ទប់របស់គាត់ផងមានប្រហែលជាពីរពាន់ដុល្លា(២០០០)ទៅបីពាន់ប្រាំងបីរយហាសិបដុល្លា(៣៨៥០ដុល្លា)ទៀត។
ក៖ ចាស!
ខ៖ ធ្វើអោយគាត់ហ្នឹង។
ក៖ លោកតាចឹងការកាន់សាសនាព្រះពុទ្ធសាសនានឹងដូចជា
សំរាប់ជីវិតរបស់លោកតាបានជះឥទ្ធិពលអ្វីខ្លះដែរសំរាប់ផ្លូវចិត្តនិងផ្លូវអារម្មណ៍ហើយនឹងជីវិតរបស់លោកតាតាំងពីមុនមកដល់ពេលឥឡូវនេះនឹង?
ខ៖
ខ្ញុំមានជះផ្លូវចិត្តដែរហេតុអីបានថាជះផ្លូវចិត្តឧទាហរណ៍ដូចជាយើងខ្ញុំនឹងណាជាមេដឹកនាំនៅក្នុងវត្តក្រាំង ឃុំព្រៃសន្លឹក នៅក្នុងស្រុកពារាំង នៅក្នុងខេត្តព្រៃវែងថាខ្ញុំចង់ធ្វើនេះមួយជាកើ្តដំណែលជាមរដកនៅក្នុងសាសនាដែលគេមិនសូវធ្វើណា
ដល់គេមិនសូវជាបានធ្វើចឹងក៏យើងពុះកញ្ជោរនៅក្នុងការផ្តួចផ្តើមជួយដឹកនាំព័

មយួរដែលគេហៅថាឧបករណ៍សំរាប់ប្រើប្រាស់នៅក្នុងកម្មវិធីកសាងអ្វីសំរាប់ផាមរកដ៍សំរាប់សាសនានឹងខ្ញុំបានខំប្រឹងប្រែចឹងទៅគេមិនសូវត្រូវអីចឹងខ្ញុំវាពិកបាកដែរ។(សើច)
ក៖
ចាសត្រូវហើយកុង!ចាសចឹងក្រុមគ្រួសាររបស់លោកតាគាត់ជឿលើសាសនាព្រះពុទ្ធសាសនាទាំងអស់គ្នា?
ខ៖ អូ!គាត់ជឿណាស់។
ក៖
ចឹងមានប្រពៃណីអ្វីខ្លះដែរក្រុមគ្រួសាររបស់លោកតាដែលតែងតែបានអនុវត្តន៍នៅក្នុងសាសនាព្រះពុទ្ធ?
ខ៖
គាត់គ្មានប្រពៃណីស្អីនោះទេគាត់គ្រាន់តែថាជឿលើផ្លូវព្រះពុទ្ធសាសនាគាត់ដឹងតែឃើញព្រះសង្ឃអីចឹងគាត់បានជួយបំបួសអីចឹងដល់ពេលមានបិណ្ឌបាទគាត់ជួយដាក់បាតចឹងទៅដល់ពេលមានខែដាក់បិណ្ឌទានអីនឹងគាត់ទៅ។
ក៖ ចាស!
ខ៖ គ្មានស្អីសំរាប់នឹងប្រែក្រឡាសអីនោះទេបាទ!គ្រាន់តែចឹង។
ក៖ ចាសត្រូវហើយលោកតា!ចឹងអីសាសនាដែលមាននៅក្នុងជំនាន់អាពតវិញតើកាលនុងគេបានជំលាសក្រុមគ្រួសាររបស់លោកតាទៅឯណាដែរ?
ខ៖
បាទ!កាលពីថ្ងៃអី!..១២ខែមករាខែប៉ុន្មានតែណែកដែលគេបានជំលាសទៅចេញពីភូមិក្រាំងទៅស្នាក់នៅអី!...ទួលក្អោកបានមួយយប់
ចេញពីទួលក្អោកទៅស្នាក់នៅវត្តនៅក្នុងភូមិឧទីនោះបានប៉ុន្មានយប់ចេញពីនុងទៅដល់ភូមិមៀនកំពុងស្វាយក្បែរអូររាំងឪឯណោះនៅប៉ុន្មានថ្ងៃឯនុងជិតបានដល់ថ្ងៃ៦មករាបានគេប្រកាសថា៧មករាគេបានរំដោះនឹងបានពីរថ្ងៃនៅថ្ងៃទី៨នឹងទី៩បានគេមកដល់ក្នុងស្រុកវិញ។
ក៖ ហឹ!
ខ៖ មកដល់ឃើញថាមាន់នៅមួយៗ។
ក៖
លោកតាកាលនុងដូចជាលោកតាបានឃើញអាពពតយកមនុស្សទៅសំលាប់ចោលដែរឬទេលោកតា?
ខ៖ អូ!...ខ្ញុំពេញតែម្តងមានអណ្តូង១ប៉ុណ្ណឹង!
មើលទៅឆ្ងាយពីផ្ទះរបស់ខ្ញុំប្រហែលជាជាងកន្លះគីឡូកូនអើយ។ទៅដល់កូនអើយគួរអោយអាណោកអាភមណាស់និយាយពីគ្រាប់ភ្នែកឡើងប៉ោកប៉ិនៗនែកប៉ិនគ្រាប់ឃ្លីណាព្រោះអីពេលនឹងវាបានហឹម
ដូចជាមកតាមទឹកទន្លេនៅក្នុងខែនឹងណាដែលមានទឹកឡើងមកនោះ!
កូនអើយឡើងពេញអណ្តូង
ស្អុយមិនជិតនោះទេប្រហែលជាចង់កន្លះគីឡូឯនុងរឿងស្អុយ!វែមនុស្សចោលអត់អំពើណា។អានេះយុងខ្ទងណាស់!បានថាខ្ញុំឆ្អែកហើយតែខ្ញុំគេចខ្ញុំគេចរហូតនឹងខ្ញុំបានសំគេ
គ្មានអីធំជាងម្រាមដៃ១០នោះទេហែងនឹងវាកាចយ៉ាងណាខ្ញុំបានសំពះគេបានអោយរួចខ្លួនរហូត។(សើច)
ក៖ (សើច)ចឹងកាលនុងគេបានធ្លាប់ធ្វើបាបដល់លោកតាដែរឬទេកាលនុង?
ខ៖
ធ្លាប់!បាទគេបានរករឿងដល់ខ្ញុំសូម្បីតែខ្ញុំពាក់អាវខ្មៅកាលនុងគេហៅថាពាក្យឃើងណា! គេថា១៧មេសា
ពួក១៧មេសាគេបានជំលាស់ចេញភ្នំពេញចឹងទៅគេបានទៅស្នាក់នៅ

ឯភូមិខ្ញុំដល់ពេលហើយចឹងទៅក៏គេអោយទៅនៅឯនែកនៅឯស្រុកគៀនស្វាយនុងនៅជីតនេះ ដល់ពេលហើយទៅកាលនុងគេបានអោយខ្ញុំពាក់អាវខ្មៅ រួចហើយបងស្រីគាត់មានឈ្មោះបងយ៉ងៗ ប៉ុន្តែប្តីរបស់ខ្ញុំមានឈ្មោះថា គោក បងយ៉ងគាត់ប្រាប់ដល់ខ្ញុំថា បងអ៊ីនណែកហើយខ្ញុំថាម៉េចនុង បងឯងបងឯទីនេះមើលអាវខ្មៅថ្មេរចេសពាណ៌សម៉េចនុង? មកនេះខ្ញុំដាក់ពណ៌អោយចឹងទៅគាត់បានធ្វើយ៉ាងម៉េចនោះទេគាត់បានលាប អីក៏មិនដឹង ថ្មេរអាវខ្មៅថ្មេរសនឹងគាត់បានលាបអោយចេញពណ៌ខៀវ។

កៈ ហឺស!ចឹងខុសគេចឹងប្រយ័ត្ន។

ខៈ
បាទ!ដល់ហើយទៅមានប្រធានសហករគេនឹងបានហៅខ្ញុំទៅអប់រំហៅទៅប្រាប់អោយរំអប់ប្រដៅបាន៤ទៅ៥ឆ្នាំឡើងគេអោយសូមខ្ញុំនឹងដូរយកអាវនឹងទៅទុក។

កៈចាស!

ខៈហើយគេមិនអោយខ្ញុំពាក់នោះទេព្រោះអីអាវនុងវាស្អាត!

កៈ នឹងហើយ!

ខៈ ស្អាតណាស់! ម៉ូត...

កៈ ម៉ូតវាយ៉ាងម៉េចទៅលោកតា?

ខៈ បាទ?

កៈ ម៉ូតរបស់វាមានកយ៉ាងម៉េចដែរ?

ខៈ អូ!អាវពីសម័យនឹងធម្មតា។

កៈ ប៉ុន្តែអាវវាស្អាត?

ខៈ បាទ!អាវវាស្អាតណាស់គេដេរ វាររៀប(ដូចជា)អាវរាងគេណា។

កៈ អូ!

ខៈ ស្អាតដែលម្តងនឹងកាលនុង! ស្អាតជាងអាវប្រធានសហករ។

កៈអូ!ចឹងបានគាត់...

ខៈ
ស្អាតជាងអាវសន្តិសុខពេលខ្ញុំពាក់ទៅនឹងវាស្អាតនុងហើយ!ហើយខ្ញុំមិនដឹងថាយ៉ាងម៉េចនោះទេកូន បានធ្វើជាអនុប្រធាន បងសឹងរ៉េតប្រធាន
ខ្ញុំជាអឿននឹងអនុ
នោងគឺមជាសមាជិកមានចំនួនបាន៣នាក់នុង។គេមានប្រពន្ធនោះទេ តែចំណែកឯខ្ញុំនោះទេដែលមាន២នាក់នោះគេនៅជាកំលោះនៅឡើយនោះទេ!
គេអោយធ្វើជាប្រធានយុវជន
ហើយចឹងខ្ញុំក៏គេអោយធ្វើជាប្រធានយុវជនដែរដល់ទៅហើយគេអោយទៅកាប់ព្រៃអីណា!មានកងចល័តក្មេងស្រែក
មានខ្លះល្បាក់ប៉ុនកូនឯងខ្លះទៅក្មេងជាងកូនឯងហើយមានខ្លះទៅក៏ចាស់ជាងកូនឯងតិចអីចឹង!
អូ...គឺថាស្រលាញ់ខ្ញុំចឹងខ្ញុំមិនចេះខ្វះអីសំរាប់ស៊ីនោះទេកាលនុង
ខ្លះយកស្ករផែនយកទៅអោយស៊ីទៅ
ខ្លះបានឃើញអាវខ្ញុំដែលមានអាវខោរហែកគេប្រាប់ខ្ញុំថាស្អែកយកខោអាវនឹងយកទៅបោកអោយចាំថ្ងៃស្អែកខ្ញុំដេរអោយព្រោះអីពេលនឹងយើនៅឆ្ងាយពីក្នុងស្រុកនោះ។

កៈ ចាស!

ខៈចឹងកាលនុងខ្ញុំបានទៅណាខ្ញុំបានលើកដៃសំពះគេរហូត។

កៈ
ចាសកុង!ចឹងទាក់ទងនឹងជីវិតរបស់កុងពេលដែលបានដាច់មកនៅក្នុងសម័យអាពតនឹងកុងមាននៅចាំទិដ្ឋភាពអីជាងគេដែលវាបានធ្វើអោយកុងបានចង់ចាំរហូតមកដល់ពេលសព្វថ្ងៃនេះ?

ខៈ នៅជំនាន់ពពតហេស៎?

ក៖ចាស!
ខ៖
ខ្ញុំចាំថាថៃសនោះទេកូន!កាលនុងខ្ញុំបាននៅចាំច្បាស់ណាស់ហេតុអីថាបាននៅ
ចាំច្បាស់នៅកន្លែងនុង! ខ្ញុំសួរថា មេកម្មាធិការជាអ្នកដឹកនាំនៅក្នុងសម័យនោះ
អំបិលមាននៅក្នុងឃាំងមាន មើលទៅឃើញឡើងសស្កុស។
ក៖ ហឹស!
ខ៖
នៅឡើង១ប៉េៗហេតុអ្វីអីក៏មិនអោយអ្នកនៅក្នុងរោងបាយនៅឯក្នុងកន្លែងនុង
មិនអោយយកមកស៊ី?ទី១ហ្នឹងណា!
ហើយមានទី២ស្រូវខ្ញុំណាមានបងប្អូនសហករក្រុមទី១និងក្រុមទី២ក្រុមរហូតដល់ទី
១០លីស្រូវយកទៅទុកនៅឯក្នុងឃាំងគរហែងអូ!...អាណាលីស្រូវ១ជាំរមិនរួចហៅហែ
ងនឹងទៅអប់រំទៀតហើយស្រូវឡើងយកទៅឯណាមិនអស់គរហែងអូ...២០០ជាំរទៅ
៥០០ជាំរអីនៅ១កន្លែងៗណា!ហើយអោយគេបាន១កំប៉ុងអីសំរាប់បបរនៅក្នុង១
ខ្ទះដើម្បីយកទៅចែកគ្នាស៊ី!
ដែអាឡែងស្អីគេស្លកដែលវាលេចនោះយើងយកវាមកដើម្បីនឹងត្រងទឹកផឹកណា!
ខ្លាចអស់ខ្លាចមិនឆ្អែកណាកូន!សួរថារឿងអីអាហ្នឹងដែលអោយយើងបាននៅចង់
ចាំធ្វើបាបខ្មែរគ្នាឯងសោះនឹងមិនមែនជាអ្នកណានុងគេដូចថាខ្ញុំធ្វើបាបចៅឯ
ងហ្នឹងហើយលែងចុងអំបិលឃើញសស្លុសចឹងមើលទៅឡើងហៀរគ្នារបស់វាទៅកន្ល
ងជាន់នៅឯនុងមិនអោយយើងស៊ី។
ក៖ហឹស!
ខ៖ អោយយើងស៊ីសាប បបរសាប។
ក៖ចុះកាលនុងកុងបានធ្លាប់សួរដល់គេចឹង?
ខ៖នរណាទៅហ៊ានសួរ!
ក៖ តែបាននឹកនៅក្នុងចិត្តណ៎កុង?
ខ៖នឹកនៅក្នុងចិត្តហេតុអ្វីបានជាគេមិនអោយស៊ី! ចឹងណាហើយមិនមែន
ចម្លើយនេះមិនមែនតែរូបខ្ញុំនោះទេកូនឯងទៅសួរ។
ក៖ចាសត្រូវហើយចាស់ៗកាលនៅជំនាន់នុង!...
ខ៖
ប៉ុន្តែវាចេះតែអ្នកនៅខាងខេត្តតាកែវឬក៏នៅក្នុងខេត្តបាត់ដំបងគេបានអោយ
យើងស៊ីឯចំណែកឯនៅក្នុងភូមិក្រាំង ឃុំព្រៃសន្លឹក នៅក្នុងស្រុកពារាំង
នៅក្នុងខេត្តព្រៃវែងមិនអោយស៊ីនៅក្នុងឃុំក្រចំ ភូមិរៀប
ឃុំរកាអីនឹងអត់ទាំងអស់គ្នា? នៅក្នុង ឃុំព្រៃសន្លឹកអត់ នៅក្នុងស្រុកពារាំង
នៅក្នុងខេត្តព្រៃវែងអត់?
ក៖ នៅក្នុងកាលនុងកុងធ្វើជាយ៉ាងណាបានដឹងពត៌មាន?
ខ៖ កាលនុងខ្ញុំជាប្រធានយុវជន។
ក៖ ចាស!នឹងហើយគេបានហៅទៅប្រជុំបានដឹងពត៌មាននឹងហេស៎កុង?
ខ៖ដឹង!
ក៖គេបានសួរយោបល់ពីខាងយើងដែរឬទេកុង?
ខ៖
អូ!...នរណាទៅហ៊ានកាលនុងគេមិនទៅសួរអីពីយើងនោះទេ!គេមិនអោយសួរគ្នា
នោះទេ។
ក៖ដឹងតែថ្នាក់លើដែលគេបានបញ្ជាមក?
ខ៖
ដឹងតែសហករមេប្រធានសហករធំៗនោះទេ!បានត្រឹមតែចៅសង្កាត់មេឃុំមេអី
នោះទេហើយយើងនេះគឺអត់នោះទេ។
ក៖ហើយប្រធានសហករនឹងនៅក្នុងភូមិនឹងដែរ?
ខ៖ នៅក្នុងភូមិនឹងជាមួយគ្នា ឈ្មោះថាពូជុំ។

កៈ

តែគាត់អត់មានបានប្រាប់អីដូចជាដំណឹងអីដល់អី...អ្នកដែលនៅខាងក្រោមនឹងគឺអត់មានទេកុង?

ខៈ

គ្មាននោះទេពេលនុងគាត់ស៊ីអីនៅជាមួយនឹងពួកយើងដែលតែដល់ពេលយប់គាត់ទៅស៊ីអីនៅក្នុងបន្ទប់របស់គាត់។

កៈ (សើច)ចឹងគាត់មានរបបរបស់គាត់ផ្សេងទៀត?

ខៈ

ស៊ីកណ្ដាលទ្រូងរបស់តែខ្លួនឯងនុងបានអោយតែឆ្អែក!បើវាលាក់ពីយើងព្រោះអីយើងទៅដេកអីអស់ហើយ។

កៈចាស!

ខៈ

ចេញពីរោងបាយទៅមានជួងលីសួរម៉ឺងៗ!ចឹងវាស៊ីអីនៅជាមួយគ្នាទៅនៅក្នុងរោងបាយប្រហែលជា៦ទៅ៧នាក់។

កៈហឹ!

ខៈស៊ីអីបានតាមចិត្តនឹងកាលនុងមានបាយក៏មានស្រាប់ បារីក៏មានជក់ ស្ករក៏មានស៊ី មាន១កំផ្លេរ។

កៈ ធ្វើបាបតែប្រជាជនឯង!

ខៈ

បាទ!ធ្វើបាបប្រជាជន!ចឹងបានជាកូនឯងបានសួរមុននឹងមិញថាអ្វីដែលចង់ចាំ?

គឺខ្ញុំចង់ចាំមិនភ្លេចនោះទេហេតុអ្វីបានបង្អត់ខ្មែរ!បាទ!ហេតុអ្វីបានបង្អត់ខ្មែរសួរថានុងជាមនុស្សដែរឬក៏អត់?

ជាមនុស្សដូចតែគ្នាទេតើមិនគួណាទៅធ្វើចឹងនោះទេ។

កៈ

ត្រូវហើយ!ដល់ពេលនៅក្នុងការចង់ចាំនឹងវាលំបាកចឹងហើយដល់ពេលដែលបានដាច់មកទៀតវារឹតតែពិបាកនោះថែមទៀតហើយកុងព្រោះអីត្រូវរត់ចេញត្រូវអីនោះកុងកាលនុង?

ខៈ

អូ!...ខ្ញុំហឹស!បើសិនជាមានផ្លូវរត់ចេញនោះហេស់កុំទៅថាចំងាយរហូតដល់ស្រុកថៃឬក៏ស្រុកអី!អឺ!អីគេនែកបុរេ(កូរ៉េ)អីណា។

កៈ(សើច)ប្រទេសកូរ៉េ!

ខៈ

បើសិនជាដើរទៅដល់នឹងខ្ញុំទៅមិនថាអ្នកឯនៅចំងាយប៉ុននុងនោះទេ!ខ្ញុំទៅហើយ។

កៈ

ចុះកុងកាលនុងមានបានធ្លាប់គិតថាចង់អោយរួចដាច់ពីពពតភ្លែមៗទេកុង?

ខៈ

អូយ!...និយាយថាមិនគិតម៉េចកូនបើសិនជាវាជួចត់យ៉ាងនេះប្រើគ្នាស្មើនឹងសត្វណា។

កៈហឹស!

ខៈ ស្មើនឹងសត្វ

រហាត់ជាន់ចឹង!ទៅហើយជាន់!!ឯងជាន់៣ទៅ៤ម៉ោងដល់ពេលគ្នាចុះមកឈប់ថាវារួយជើងគេមកចុះច្របាច់អីតិចចឹងបើសិនជាវាបានឃើញវិញនុងមិនបាច់នោះទេ! វាស្ដីអោយយើង

ធ្វើទារុណកម្មមនុស្សដែលគ្មានទោសនោះវាពិបាកណាស់!ចឹងបានគេដល់ពេលក្រោយមកនឹងបានលឺគេថាមានគុកតែអត់មានជញ្ជាំង!

ជូរចត់ណា!ខ្ញុំសួរដល់កូនឯងចេសវិញថាហេតុអីកើតជាកូនខ្មែរចៅឯងនឹងក៏ជាកូនចៅក្រុមគ្រួសាររបស់ខ្ញុំដែលនេះប៉ុន្តែគ្រាន់តែថាវាឆ្ងាយមិនដឹងថានៅក្នុងជំនាន់កាល។
ក៖ចាសកុង!
ខ៖បាទ!ហើយចេះធ្វើបាបគ្នាកើតអត់អោយគ្នាស៊ីបាយ!
បាយវាមានម៉ាកាណរហើយអំបិលវាមានម៉ាកាណរ។
ក៖
ចាស!ចឹងបន្ទាប់មកតើកុងអាចប្រាប់បានទេថាបញ្ហានៅក្នុងជីវិតដែលកុងបានជួបប្រទះផ្សេងៗដែលវាបានធ្វើអោយកុងនឹកចាំមកនៅក្នុងជីវិតរបស់កុងមានអ្វីខ្លះដែរ?
ខ៖
អត់នោះទេ!គ្រាន់តែថាជីវិតរបស់ខ្ញុំដែលដឹងថាពេលនៅក្នុង៣ឆ្នាំ៨ខែ២០ថ្ងៃនេះណាទោះបីជាអ្នកឯងដែលស្អាតដូចជាទេវតាទោះបីជាអ្នកឯងមានចិត្តស្លូតបូតដែលគេហៅថាជាមនុស្សមានចិត្តជាបុណ្យជាធម៌ជាបុណ្យយ៉ាងណាក៏ដោយក៏ខ្ញុំមិនជឿដែល
អោយតែនៅក្នុងរបប៣ឆ្នាំ៨ខែ២០នឹងគឺខ្ញុំបានចងចាំអស់មួយជីវិតនិយាយផ្តាំផ្ញើដល់កូនចៅកុំអោយឈានចូលទៅដល់អាកន្លែងនុងគគ្រេចណាស់នុងហើយស្អប់ណាស់ខ្មែរសោះសម្លាប់ខ្មែរ! ខ្មែរសោះសម្លាប់ខ្មែរ! ខ្មែរសោះបង្អត់ខ្មែរ!
សុទ្ធតែគ្នាឯងសោះគេបានអោយធ្វើជាប្រធានសហករនឹងក៏ជាខ្មែរ!
ខ្ញុំរស់នៅជាកសិករគឺជាខ្មែរហើយអាអ្នកដែលលើកប្រពន្ធទឹកក៏ជាខ្មែរ!
ហើយអាអ្នកដែលជីកអាងទឹកក៏ខ្មែរ។
ក៖
ហឺស!កុងអើយកាលនុងមិនដឹងជាយ៉ាងម៉េចខ្ញុំក៏ឆ្ងល់ដែលនុងកាលនុងដូចជាមានស្អីគេចូលយ៉ាងម៉េចនោះទេទៅចឹងទៅ?
ខ៖
ហ្នឹងហើយ!ដូចជាមានមរនោគមន៍វិជ្ជាស្អីគេវាបានយកមនុស្សទៅសម្លាប់ចោល។
ក៖ ហ្នឹងហើយពេលនោះគឺក្មេងៗនោះទេ
តាមខ្ញុំបានមើលឯកសារអីកាលនុងមានខ្លះក្មេងៗនោះទេដែលយកមនុស្សទៅសម្លាប់...
ខ៖ បាទ!
ក៖
ជួនកាលក្មេងៗអត់សូវនឹងបានដឹងអីចឹងបានសម្លាប់ទៅកាន់កាំភ្លើងអីទៅបានសម្លាប់ដោយកាន់កាំភ្លើងអីអូសដើរ។
ខ៖ នុងហើយ!ក្មេងៗនឹងដែលវាបានយកចាស់ៗទៅសម្លាប់ចោល។
ក៖កាលនុងដូចជាបានបាក់ស្បាតអស់បានហ៊ានអីជាមួយនឹងគេចឹង។
ខ៖
អត់ហ៊ាននុងទេមនុស្សកាលជំនាននុងជឿគេណាស់!ហើយខ្លាចគេណាស់បើសិនជាគេថាខុសគឺខុសហើយមិនហ៊ាននឹងគេនោះទេ!ព្រោះអីខ្លាចគេ!មិនមែនដូចជានៅក្នុងសម័យបច្ចុប្បន្ននឹងដើរទៅឃើញប៉ូលីសអីចឹងដើរចង់ជាន់ប៉ូលីសអីចឹងនោះទេ។
ក៖ ដល់ពេលឥឡូវនេះគឺលែងសូវខ្លាចហើយ?
ខ៖ ឥឡូវលែងខ្លាចហើយ។
ក៖ចាស!
ខ៖
អូ!...កាលនៅក្នុងជំនាន់ខ្ញុំនោះកូនអើយវាជូរចត់ណាស់ខ្ញុំណា!ឡើងត្នោតនៅក្នុងសហករកាលនុងអាស្រែង
អាឌីស្រែងនឹងគេបានអោយវាទៅធ្វើជាប្រធានជាមួយនឹងអាឌីសន ហើយខ្ញុំ

អាកុង អាលៃហេង អីអាផន តាធន (ដែលពីណាទៀតទេដែលបានឡើងត្នោត)
តាកុងលន មកដល់ឥឡូវគាត់បានស្លាប់ហើយ!
ឡើងត្នោតហើយនឹងខ្ញុំបានលបខ្សឹបថាអាចៅឯងទៅឯណានុង?
អូ!តាខ្ញុំទៅយកគោ ចៅឯងផឹកទឹកត្នោតនេស!
កាលនុងខ្ញុំនៅឯចុងឯនោះចឹងកាលនុងគាត់ថាផឹកទឹកត្នោតទៅ
ដល់ពេលថ្ងៃឡើងគេឃើញមិនបានដឹងថាមានពីណាគេឃើញនោះទេ!
គេបានហៅខ្ញុំទៅសួរថាអោយទឹកត្នោតអោយគេផឹកប៉ុន្មាននាក់រាល់ថ្ងៃ?
ក:ហឹស!
ខ:
អូហូយ!...ទៅប្រាប់ខ្ញុំថាវីដណាវាបានដើរមកនុងហើយដល់ពេលល្ងាចហើយចឹងក៏
ខ្ញុំដាក់នៅឯនុងចឹងគ្រែនលោវាស្រែកវាផឹកទៅវាម៉េច? គេថា
គេអោយធ្វើអោយអ្នកនុងផឹកឬក៏អី? គេបានរកដល់ខ្ញុំនឹងណា?
ក: ហឹស!
ខ: គេសួរខ្ញុំណា។
ក: នុងហើយ!
ខ: មិនមែននោះទេ!
ខ្ញុំសុំទោសធ្វើយ៉ាងម៉េចបើសិនជាវាសុំក៏ខ្ញុំអោយវាផឹកទៅការពិតទៅនឹងកាលនុ
ងខ្ញុំបានអោយវាផឹកនោះទេកាលនុងមិនមែនអោយវាផឹកនោះទេ(សើច)។
ក:នឹងហើយ!(សើច)ចាស!
ខ: ចឹងទៅគេបានរករឿងដល់ខ្ញុំគេថា ទេកូន!
ហើយសំរាប់ខ្លួនឯងនុងកាលនុងបានស្ករហើយយកវាទៅចាក់ជាស្ករផែនហូស!...ប៉ុ
នៗនេះ។
ក:ចាស!
ខ: មិនបានដឹងថាបានប៉ុន្មានម៉ឺនសែនផែននោះទេ!
ស្មានតែខ្ញុំនឹងទៅបាន១យកមកធ្វើកូនប្រពន្ធអីនោះឯផ្ទះ?
ក:អត់ទៀត!
ខ:
អត់នោះផង!បាទ!ចាក់ហើយនឹងគ្នាវានៅឯនោះហើយយកទៅដាក់នៅឯឃាំង
ទៅដាក់នៅឯកញ្ឆែអី។
ក:ចាសកាលនុងកាលតែនៅក្នុងឃាំង?
ខ:បាទ!
ក:ចឹងធ្វើយ៉ាងម៉េចទៅឃ្លាំនុងពេលដែលបានដាច់ពីអាពតមក?
ខ:បាទ!ដល់ពេលដែលបានដាច់ហើយគេបានយកដណ្តើមគ្នាយកថ្លឹងយក
ទៅមានខ្លះយកជញ្ជីងទៅ ខ្លះយកពាងទៅហើយអាខ្លះយកស្ករទៅ(សើច)។
ក:យកអស់ទៅ?
ខ: យកអស់ទៅ!
ក:ចុះកាលនុងកុងបានអីគេដែរ?(សើច)
ខ: កាលនុងខ្ញុំគ្មានទៅបានស្អីព្រោះអីកាលនុងខ្ញុំទើមតែមកពីស្រុកដំរិលពី
ស្រុកអូរាំងឪ មកឆ្ងាយដែលកាលនុងមកដល់ក្រោយគេ!
តែវាមិនអត់នោះទេកាលនុងបានល្អិ
បានកង់កញ្ជាស់១យកមកធ្វើហើយផ្លាស់កៅស៊ូ
កៅអីចឹងទៅយកមកដើម្បីប្តូរជាសសរ ខ្ញុំក្រណាស់
ខ្ញុំបានទិញមាសបានប៉ុន្មានជីហើយខ្ញុំបានទិញកង់មួយសំរាប់រកស៊ីពេលដែលបា
នបែកភ្នំពេញមកកុំអីដាប់បាត់ទៅហើយ។
ក:ខ្ញុំសូមសរសើរចាស់!ៗនៅពីជំនាន់ដើមមែនទែនសូម្បីតែម៉ាក់របស់ខ្ញុំយាយខ្ញុំ
កាលនុងម៉ាក់របស់ខ្ញុំគាត់បាននៅរាងក្មេងៗប៉ុន្តែយាយរបស់ខ្ញុំជាយាយទួតអីគា
ត់នៅចង់ចាំកាលនៅសម័យនុងហើយកគាត់បានតស៊ូរហូតហើយក៏គាត់បានមា

នជីវៈភាពរាងគ្រាន់បើដែលដើម្បីទុកអោយកូនចៅជំនាន់ក្រោយមកទៀតចឹងណាកុង!។
ខៈបាទ!
កៈ
ចាសចឹងសំរាប់បទពិសោធន៍ល្អៗវិញចឹងតើកុងមានបទពិសោធន៍ល្អៗអ្វីគេខ្លះដែរនៅក្នុងជីវិតរបស់កុង?
ខៈ
បទពិសោធន៍ល្អៗនោះមកដល់ពេលឥឡូវនឹងគឺមានតែប៉ុណ្ណឹងនោះទេគ្រាន់តែថាបេះដូងរបស់ខ្ញុំ សព្វថ្ងៃនេះនឹងខ្ញុំបានមានឧត្តមគតិថា
អញមកដល់សព្វថ្ងៃនេះនឹងគឺដាច់ខាតមិនធ្វើជាគំរូអាក្រក់ដល់គេនោះទេ
អញធ្វើយ៉ាងម៉េចគឺជាគំរូល្អ
សូម្បីតែកាលបទជើងនៅក្បែរលោកទេសនាដែលលោកបានចំរើនព្រះបរិតទៅកម្មវិធីបុណ្យក៍ខ្ញុំធ្វើអោយសមរម្យ ជាមនុស្សមួយដែលល្អ
សំរាប់អោយអ្នកជំនាន់ក្រោយគេបានមើលហើយគេបានដើរតាមយើងគេក្មេងគេឃើញថាអូ!លោកតានោះពេលទៅក្នុងកម្មវិធីបុណ្យបច្ច័យ៤វាចេះៗ!រៀបចំកម្មវិធី ធ្វើពិធីអោយគេចេះៗ!
អឺៗ!ចឹងសព្វគ្រាប់រៀបប្រគេនព្រះសង្ឃគេបានធ្វើយ៉ាងម៉េច!ដាលឆ្លងគេបានធ្វើយ៉ាងម៉េច ពេលដាលនឹងឆ្លងយើងត្រូវធ្វើយ៉ាងម៉េច
ចឹងយើងត្រុវតែធ្វើទៅតាមនឹងអានុងរាទី១និងទី២ណា!អាពេលដែលយើងបានដើរលេងក្មេងវាចេះតែតាមមើលហើយណា!
មើលរបៀបរបបរបស់យើងនឹងវាយ៉ាងម៉េចថាមានពាក្យឯងណាដែលវាបានសមរម្យដែលមានពាក្យណាដែលមិនសមរម្យ
ហើយពាក្យណាដែលសំរាប់ប្រដាំក្មេងហើយពាក្យឯណាដែលមិនសមរម្យយើងកុំនិយាយធ្វើយ៉ាងម៉េចអោយវាបានល្អ។
កៈចាស!
ខៈ
បាទ!ធ្វើយ៉ាងម៉េចអោយបានល្អកូន!ខ្ញុំណាខ្ញុំគិតយ៉ាងយូរ៥ឆ្នាំទៅ១០អីទៀតនឹងខ្ញុំងាប់បាត់ទៅហើយ!ខ្ញុំអត់មានការលោបលន់អីមិនមែនទើបតែ៥ទៅ៦ឆ្នាំទៀតនោះទេ!
ខ្ញុំបានគិតតាំងពីខ្ញុំបានមានអាយុបាន៤៥ឆ្នាំមកនឹងពេលដែលខ្ញុំបានចូលសុំជម៌មកគឺខ្ញុំមិនលោបនោះទេ!
តាមលទ្ធភាពប្រាជ្ញារបស់ខ្ញុំអាចធ្វើបានប៉ុណ្ណាខ្ញុំធ្វើប៉ុណ្ណឹង!អោយលោបនោះខ្ញុំមិនលោបនោះទេព្រោះអីខ្ញុំឃើញច្រើនណាស់ខ្លះទៅ! អាខ្លះបានតែខោខ្លីទៅ
ហើយអាខ្លះទៀតទទេរក៏មានដែរ អាខ្លះមានអាវវែងគេបានបំពាក់អោយទៅ
អាខ្លះលុយរាប់រាល់រាប់លានកោដរាល់ឡានអីតែថាបានយកទៅដែលឬទេ?
អត់ទេ!
កៈនឹងហើយ!
ខៈ
ទៅលោបចង់បានរបស់ទ្រព្យគេមកធ្វើអីងាប់អីបានតែទទេរនឹង!ចឹងបាទ!ខ្ញុំថាអត់ប៉ង់ប្រាថ្នាធំជាងសមាតិភាពរបស់ខ្ញុំនោះទេ។
កៈ
ចាស!ប៉ុន្នែកុងមានរឿងឯណាដែលបានធ្វើអោយកុងបានសប្បាយចិត្តដែលឬទេនៅក្នុងជីវិតរបស់កុងដែលពេលកុងបាននឹកឃើញហើយវាបានធ្វើអោយកុងបានសប្បាយចិត្តតែម្តងណា?
ខៈ
មានតើ!ដែលថាមានរឿងដែលធ្វើអោយសប្បាយចិត្តខ្ញុំចង់និយាយថាអាអ្វីដែលធ្វើអោយសប្បាយចិត្តនោះមិនមែននិយាយតែមាត់នោះទេនិយាយពីក្រអៅបេះដូ

ង! ចង់និយាយថាប្រទេសជាតិទាំងឡាយណាក៏ដោយសូម្បីថាកម្ពុជាតិ ឬក៏ថៃ ឬក៏ឡាវ ឬក៏យួន អាមេរិកាំង
អូស្រាលីចង់តែថាកន្លែងនុងអោយតែប្រជាពលរដ្ឋបានសុខដមរមណារត់ចូលច្រកនៅឯក្នុងចូលថាស្រះនឹងកុំអោយមានត្រីឆ្តោរវាត្របាក់
អាកូនតូចក៏វាសប្បាយអាធំក៏សប្បាយដល់ពេលអាធំពេលត្រែលនៅឯនេះទៅហើយអាធំក្រាញក្រចុសសណ្តាលមកឯនោះមក!
កុំអោយត្របាក់គ្នាទៅបំពុលពេញទាំងស្រះ! ខ្ញុំចង់និយាយចឹង។
ក:ចាស!
ខ:បាទ!ខ្ញុំចង់អោយបានសុខសាន្ត។
ក:បានសុខសាន្តទាំងអស់គ្នា។
ខ:បាទ!កុំអោយមានពីណាហួស!បានស្អប់ទាំងជំនាន់អាពពតទៀតទៅ!
ក:ចាស!
ខ: ខ្ញុំស្អប់តែម្តង!
ក: ចឹងកុងពេលដែលកុងពិបាកចិត្តអីតើកុងតែធ្វើអ្វីខ្លះដែរ?
ខ: ខ្ញុំពិបាកចិត្តនឹងគឺខ្ញុំបានគិតថាចឹស!
ពេលដែលពិបាកចឹងខ្ញុំអូយ!ទៅរកផឹកស្រាធ្វើនេះធ្វើនោះទៅដើរលេងអីនុងអត់ទេ!គ្រាន់តែថាពេលដែលបានពិបាកចិត្តនាំគ្នានិយាយគ្នាលេងដោះស្រាយបញ្ហានេះនុង!បើសិនជារឿងថាពេលពិបាកចិត្តអោយផឹកស្រាអោយចឹងអីនោះគឺអត់មាននោះទេ!ឥឡូវនឹងពេលដែលខ្ញុំពិបាកចិត្តគឺនិយាយទៅអោយត្រង់តែម្តងនឹងសូមអោយប្រទេសខ្មែរបានសុខសាន្តកុំអោយដៀលគ្នា! រ៉ែគ្នា!
កុំអោយចាប់គ្នាចង់!
បាញ់គ្នាទៅបានហើយសូមតែប៉ុណ្ណឹង!ខ្មែរយើងណា!គ្រាន់តែចឹងកូន។
ក:ចាសកុង!ចឹងពេលដែលកុងពិបាកចិត្តកុងមកវត្តស្តាប់ធម៌ស្តាប់អី។
ខ:បាទ!ខ្ញុំនៅវត្តខ្ញុំស្តាប់ធម៌ខ្ញុំរៀន។
ក:ចាស!
ខ:ខ្ញុំរៀនក្រុងពាលីសិក្សារហូតកូន។
ក:
ចឹងកុងសប្បាយចិត្តពេលដែលកុងឃើញប្រទេសរីកចំរើនប្រទេសអី!រួបរួមគ្នាចឹងទៅ។
ខ: បាទ!អរគុណចឹងហើយ!
ក:
ចាសកុង!ជាចុងក្រោយតើកុងមានពាក្យពេចន៍អ្វីដើម្បីផ្តាំផ្ញើដល់កូនចៅជំនាន់ក្រោយទៀត?
ខ: ខ្ញុំមានហេតុអ្វីបានជាថាខ្ញុំថាមានដោយសារតែខ្ញុំចង់និយាយចេស!
ខ្ញុំចង់និយាយថាខ្ញុំបាទឈ្មោះជាអឿ
អាយុ៦៩ឆ្នាំនៅក្នុងថ្ងៃនេះរហូតទៅដល់ខ្ញុំស្លាប់បាត់ឬក៏នៅមានរស់រានមានជីវិតនៅខ្ញុំសូមផ្តាំកូនចៅក្រោយៗកុំទាល់គ្នា!ធ្វើម៉េចអោយតែល្អហើយសុខសាន្តប្រទេសទាំងអស់គ្នាសប្បាយទាំងអស់គ្នា កុំប្រព្រឹត្តអំពើអាក្រក់កុំប្រើគ្រឿងញៀន កុំសេបកាមប្រពន្ធកូនគេ កុំលួចឆន់ប្លន់គេ នាំមកនៅសេចក្តីសុខសាន្តសប្បាយគោរពគ្នាទៅវិញទៅមកឈ្មោះថាមានក្រមសីលធម៌ល្អ មានមនុស្សល្អ
មានឈ្មោះថាប្រទេសល្អហើយបាទមានតែប៉ុណ្ណឹងនោះទេអស់ហើយ។
ក:
ចាស!អរគុណច្រើនកុងដែលបានចំណាយពេលនៅក្នុងការសម្ភាសហើយទៅខ្ញុំក៏សូមជូនពរដល់កុងមានសុខភាពល្អ
ហើយនឹងក្រុមគ្រួសារទាំងអស់គ្នាមានសុភមង្គល។
ក:បាទ!សុខសាន្តកូន!
កូនឯងណាសូមអោយមានទេវតាដែលថែរក្សាទិសទាំង៨មានទេវតាថែរក្សារង់ភ

ក្រ័ក្តី បូរីកម្ពុជា សូមអោយមានពរជ័យ
បើសិនជាអត់ទាន់មានគ្រួសារតែសូមអោយជួប បុរសរូបស្អាត កូនអ្នកមាន
ណាចៅ។
ក៖ ចាស!សារធូ!!
ខ៖ អោយអាយុវែង។